# មាតិកា

## I~ខុទ្ទកាល័យព្រះមហាក្សត្រ

### ព្រះរាជក្រឹត្យ

១០-៦-២០០៦ -ព្រះរាជក្រឹត្យ នស/រកត/០៦០៦/២៦២ ស្តីពីការប្រោសព្រះរាជទានចំពោះ ឯកឧត្តម **ខិន សារិន** ជាទីប្រឹក្សាផ្ទាល់សម្តេចប្រធានព្រឹទ្ធសភា នូវគ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ ធិបឌិន្ទ ៣៨១០

១០-៦-២០០៦ -ព្រះរាជក្រឹត្យ នស/រកត/០៦០៦/២៦៣ ស្តីពីការប្រោសព្រះរាជទានប្រគេន សម្តេចព្រះពោធិវង្ស **នន្ទ ង៉ែត** នូវគ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេរីវឌ្ឍន៍ ៣៨១១

១០-៦-២០០៦ -ព្រះរាជក្រឹត្យ នស/រកត/០៦០៦/២៦៤ ស្តីពីការតម្លើងឋានន្តរស័ក្តិ នាយទាហានជាន់ខ្ពស់ នៃកងយោធពលខេមរភូមិន្ទ ៣៨១២

## II~រាជរដ្ឋាភិបាល

### អនុក្រឹត្យ

១៥-៦-២០០៦ -អនុក្រឹត្យលេខ ៥៨ អនក្រ.បក ស្តីពីការតែងតាំងសមាសភាពក្រុមការងាររបស់ក្រសួងយុត្តិធម៌ ក្នុងការងារនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ៣៨១៤

១២-៦-២០០៦ -អនុក្រឹត្យលេខ ៤១៦ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៣៨១៦

១២-៦-២០០៦ -អនុក្រឹត្យលេខ ៤១៧ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៣៨១៧

១២-៦-២០០៦ -អនុក្រឹត្យលេខ ៤១៨ អនក្រ.តត ស្តីពីការប្រគល់ភារកិច្ចជូនមន្ត្រីរាជការ ៣៨១៨

១៤-៦-២០០៦ -អនុក្រឹត្យលេខ ៤១៩ អនក្រ.តត ស្តីពីការតម្លើងឋានន្តរស័ក្តិនាយនគរបាលជាតិ ៣៨១៩

១៥-៦-២០០៦ -អនុក្រឹត្យលេខ ៤២០ អនក្រ.តត ស្តីពីការជូនមេដាយសហមេត្រី ៣៨២០

១៥-៦-២០០៦ -អនុក្រឹត្យលេខ ៤២១ អនក្រ.តត ស្តីពីការជូនមេដាយសហមេត្រី ៣៨២១

១៥-៦-២០០៦ -អនុក្រឹត្យលេខ ៤២២ អនក្រ.តត ស្តីពីការជូនមេដាយការងារ ៣៨២២

១៥-៦-២០០៦ -អនុក្រឹត្យលេខ ៤២៣ អនក្រ.តត ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ ៣៨២៤

១៥-៦-២០០៦ -អនុក្រឹត្យលេខ ៤២៤ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ៣៨២៧

១៥-៦-២០០៦ -អនុក្រឹត្យលេខ ៤២៥ អនក្រ.តត ស្តីពីការតែងតាំងក្រុមប្រឹក្សាភិបាល នៃរដ្ឋាករទឹកស្វយ័ត ក្រុងភ្នំពេញ អាណត្តិទី ៣ ៣៨២៧ **ក**

១៥-៦-២០០៦ -អនុក្រឹត្យលេខ ៤២៦ អនក្រ.តត ស្តីពីការតែងតាំងក្រុមប្រឹក្សាភិបាលកំពង់ផែស្វយ័តក្រុងព្រះសីហនុ ៣៨២៨


## III-ការងារបណ្តាក្រសួង

### ១-ធនាគារជាតិ នៃ កម្ពុជា


១០-៥-២០០៦ -ប្រកាសលេខ ធ៧-០៦ប្រក ស្តីពីការប្រើប្រាស់ និងការការពារព័ត៌មានឥណទាន ៣៨៣០


### ២-ទីស្តីការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម


០៣-៥-២០០៦ -លិខិតលេខ ១១៧៥ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ណាយស៍ ស្តារ ប្រូដាក់សិន ហៅស៍** ៣៨៥៥

០៣-៥-២០០៦ -លិខិតលេខ ១១៧៦ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **កំពត ស្តេសល អ៊ីឃើណមិក ហ្សូន** ៣៨៥៧

០៤-៥-២០០៦ -លិខិតលេខ ១១៨០ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ម៉ាស្ទ័រ ខ្មែរ ខនសាល់ធេន** ៣៨៥៩

០៤-៥-២០០៦ -លិខិតលេខ ១១៨២ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **មែប ផេស៊ីហ្វិក ទៀតណាម** ៣៨៦១

០៤-៥-២០០៦ -លិខិតលេខ ១១៨៣ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ជាសាន ខូ អិលធីឌី** ៣៨៦២

០៤-៥-២០០៦ -លិខិតលេខ ១១៨៥ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អ៊ែតវ៉ាយហ្សៃរ (ខេមបូឌា) ខូ អិលធីឌី** ៣៨៦៤

០៤-៥-២០០៦ -លិខិតលេខ ១១៨៦ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អង្គរ ទីស្តារ ត្រាវែល** ៣៨៦៦

០៤-៥-២០០៦ -លិខិតលេខ ១១៨៧ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អេឆើជីន (ខេមបូឌា) អិលធីឌី** ៣៨៦៨

០៤-៥-២០០៦ -លិខិតលេខ ១១៨៨ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ហេង សំណាង** ៣៨៧០

០៤-៥-២០០៦ -លិខិតលេខ ១១៨៩ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **លីក ឈាង** ៣៨៧២

០៤-៥-២០០៦ -លិខិតលេខ ១១៩១ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អិនធីម្ភ្លោធ័រ អិនធើណេសិនណល** ៣៨៧៤

០៤-៥-២០០៦ -លិខិតលេខ ១១៩២ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **សាន្ត សុខ ឌីវេឡុបមេន (ខេមបូឌា) (អេស.អេស.ឌី.ស៊ី)** ៣៨៧៦

០៤-៥-២០០៦ -លិខិតលេខ ១១៩៤ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **រ៉ិច ស៊ស តិធីអុី អិលធីឌី** ៣៨៧៨

០៥-៥-២០០៦ -លិខិតលេខ ១១៩៦ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ទីហ្សុីន អេស៊ា ខនស្ត្រាក់សិន** ៣៨៨០

០៥-៥-២០០៦ -លិខិតលេខ ១១៩៨ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ទិជ័យ** ៣៨៨២

នស/រកត/០៦០៦/២៦២

# ព្រះរាជក្រឹត្យ

## យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

( បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា )

ប្រោសព្រះរាជទាន

ចំពោះ

ឯកឧត្តម ជិន សារិន

ជាទីប្រឹក្សាផ្ទាល់សម្តេចប្រធានព្រឹទ្ធសភា

នូវ

គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា

ថ្នាក់ ធិបឌិន្ទ

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣៧/៧. ០៦០៦. ២៧៣

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី១០ ខែ មិថុនា ឆ្នាំ ២០០៦

លេខ : ២៤៨ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០០៦
អគ្គលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី

ឃុន ជីនកេន

# ព្រះរាជក្រឹត្យ

នស/រកត/០៦០៦/២៦៣

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

( យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃ រាជរដ្ឋាភិបាលកម្ពុជា )

## ប្រោសព្រះរាជទាន

ប្រគេន

សម្តេចព្រះពោធិវង្ស **នន្ទ ង៉ែត**

នូវ

**គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ** ថ្នាក់ **មហាសេរីវឌ្ឍន៍**

**ព្រះហស្តលេខា និងព្រះរាជលញ្ជករ**
**នរោត្តម សីហមុនី**

៣រល-០៦០៦.២៧៤

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ.ថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០០៦*

លេខ : ២៥០ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ២០០៦
អគ្គលេខាធិការរងរាជរដ្ឋាភិបាល

យុន ជិនកេន

នស/រកត/០៦០៦/៧៦៤

# ព្រះរាជក្រឹត្យ

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្សាខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើត ក្រសួងការពារជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ២០០១ ស្តីពីការកែសំរួលតួនាទី ភារកិច្ច និងរចនា សម្ព័ន្ធចាត់តាំងរបស់អគ្គបញ្ជាការដ្ឋាន នៃកងយោធពលខេមរភូមិន្ទ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១** : តម្លើងឋានន្តរស័ក្តិ នាយទាហានជាន់ខ្ពស់ នៃកងយោធពលខេមរភូមិន្ទ ដែលមានរាយនាមដូចខាងក្រោម ៖

**ក-<u>តម្លើងឋានន្តរស័ក្តិថ្នាក់ឧត្តមសេនីយ៍ទោ</u>**

| | | | |
|---|---|---|---|
| ១-ឧត្តមសេនីយ៍ត្រី | **ចាន់** | **សុខុម** | អត្តលេខ ០០០២៨៦ |
| ២-ឧត្តមសេនីយ៍ត្រី | **អ៊ុក** | **គោសា** | អត្តលេខ ០០២៧៩៥ |
| ៣-ឧត្តមសេនីយ៍ត្រី | **ចាន់** | **តារា** | អត្តលេខ ០០១១៨៥ |

**ខ-<u>តម្លើងឋានន្តរស័ក្តិថ្នាក់ឧត្តមសេនីយ៍ត្រី</u>**

| | | | |
|---|---|---|---|
| ១-វរសេនីយ៍ឯក | **អ៊ុន** | **ឱ្យរ៉ាល់** | អត្តលេខ ០០២៤៧៤ |
| ២-វរសេនីយ៍ឯក | **មឹម** | **ប៊ុនថន** | អត្តលេខ ០១៤៦៧៨ |
| ៣-វរសេនីយ៍ឯក | **កែវ** | **សារុណ** | អត្តលេខ ០០១៦៩០ |

៤-វរសេនីយ៍ឯក ឡុង តារា អត្តលេខ ០០៤២៤៥

៥-វរសេនីយ៍ឯក ជា ខា អត្តលេខ ០១២៥៧៣

៦-វរសេនីយ៍ឯក ម៉ុល ស៊ុនួន អត្តលេខ ០០៣៤១១

៧-វរសេនីយ៍ឯក ទ៊ែន ផាត អត្តលេខ ០០៤៣៧៩

**មាត្រា២ :** សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឱ្យបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា៣ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

នស.រកត.០៦០៦.២៧៥

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី១០ ខែ មិថុនា ឆ្នាំ២០០៦

លេខ : ២៥៣ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ២០០៦
អគ្គលេខាធិការរាជរដ្ឋាភិបាល
ស៊ុំ ជិនភេន

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខ :...៥៨...អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការតែងតាំងសមាសភាពក្រុមការងាររបស់ក្រសួងយុត្តិធម៌ ក្នុងការងារនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៩/នស/៩៤ ចុះថ្ងៃទី ២២ ខែ ធ្នូ ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រសួងយុត្តិធម៌
- បានឃើញអនុក្រឹត្យលេខ ៦៨ អនក្រ.បក ចុះថ្ងៃទី ០៥ ខែ ឧសភា ឆ្នាំ ២០០៥ ស្តីពីការនិរាករណ៍អនុក្រឹត្យលេខ ៤៣ អនក្រ.បក ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីការបង្កើត និង ការប្រព្រឹត្តទៅនៃលេខាធិការដ្ឋាន នៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

# ស ម្រេ ច

**មាត្រា១** : ត្រូវបានតែងតាំងសមាសភាពនៃ "ក្រុមការងាររបស់ក្រសួងយុត្តិធម៌ ក្នុងការងារនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម " ដូចខាងក្រោម :

| | | | |
|---|---|---|---|
| ១- ឯកឧត្តម | **អង្គ វង្សវឌ្ឍានា** | រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ | ប្រធាន |
| ២- ឯកឧត្តម | **ឡុង ផុល** | រដ្ឋលេខាធិការក្រសួងយុត្តិធម៌ | អនុប្រធាន |
| ៣- ឯកឧត្តម | **ហែម ក្រាញ់ តូនី** | អនុរដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី និងជាសមាជិកក្រុមប្រឹក្សាអ្នកច្បាប់ | សមាជិក |
| ៤- ឯកឧត្តម | **ច័ន្ទ មនោ** | ទីប្រឹក្សាអមក្រសួងយុត្តិធម៌ និងជានាយកខុទ្ទកាល័យរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ | សមាជិក |
| ៥- លោក | **ជីវ កេង** | ប្រធានតុលាការក្រុងភ្នំពេញ | សមាជិក |
| ៦- លោក | **ម៉ុង មុន្នីចរិយា** | ចៅក្រមតុលាការកំពូល | សមាជិក |
| ៧- លោក | **ប៉ែន ពេជ្រសាលី** | ចៅក្រម និងជាប្រធាននាយកដ្ឋានកិច្ចការអន្តរជាតិ ក្រសួងយុត្តិធម៌ | សមាជិក |
| ៨- លោក | **ប៊ុនយ៉ៃ ណារិន** | អធិការ និងជានាយខុទ្ទកាល័យរដ្ឋមន្ត្រី ក្រសួងយុត្តិធម៌ | សមាជិក |

**មាត្រា២** : បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា៣** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

*រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ មិថុនា ឆ្នាំ ២០០៦*

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល:**

- *ក្រសួងព្រះបរមរាជវាំង*
- *ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៣*
- *ឯកសារ-កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ៤១៦ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

៚

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

## សម្រេច

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនលោក **HIDEO OMORI** ប្រធានកម្មវិធី **OMORI** ដែលបានឧបត្ថម្ភថវិកាជួយសាងសង់អគារសិក្សា ០១ខ្នង មាន០៥បន្ទប់ បង្គន់អនាម័យ ០១ខ្នង មាន០២បន្ទប់ អណ្តូងទឹក ០១ និងបំពាក់សម្ភារៈគ្រប់ប្រភេទ នៅសាលាបឋមសិក្សាធ្លក ឃុំកក់ ស្រុកពញាក្រែក ខេត្តកំពង់ចាម ចំណាយអស់ទឹកប្រាក់ ចំនួន ២៦.០០០ ដុល្លារអាមេរិក ។

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និងអភិបាលខេត្តកំពង់ចាម ត្រូវអនុវត្ត អនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០០៦

នាយករដ្ឋមន្ត្រី

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
លេខៈ ៤១ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

៙

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនសប្បុរសជន ០២រូប ដែលបានបរិច្ចាគថវិកា ជួយកសាងវិទ្យាល័យ ស្រេង គីម និង ចែកអំណោយ ជូនប្រជាពលរដ្ឋ **នៅឃុំស្រង៉ែ ស្រុកព្រៃឈរ ខេត្តកំពង់ចាម** ដូចមាននាមខាងក្រោម :-

១-លោក **ចាន ចុងហាន** អគ្គនាយកក្រុមហ៊ុនកាត់ដេរ TW ថវិកា ចំនួន **១២.១៥៥** ដុល្លារ
២-លោក **ចាន់ កែស្នួន** អគ្គនាយកក្រុមហ៊ុន ម៉ាស៊ីម ថវិកា ចំនួន **១១.២៥០** ដុល្លារ

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្តកំពង់ចាម ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។ X+

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ មិថុនា ឆ្នាំ ២០០៦

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

**រាជរដ្ឋាភិបាលកម្ពុជា** **ជាតិ សាសនា ព្រះមហាក្សត្រ**

លេខៈ ៤១៧ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការប្រគល់ភារកិច្ចជូនមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**មាត្រា ១ :** ត្រូវបានប្រគល់ភារកិច្ចជូនឯកឧត្តម **ថ្វាង សុផាន់** ក្របខ័ណ្ឌទីស្តីការគណៈរដ្ឋមន្ត្រី ជាអភិបាលរងក្រុងភ្នំពេញ ។

**មាត្រា ២ :** ឯកឧត្តម **ថ្វាង សុផាន់** ត្រូវបានទទួលប្រាក់បំណាច់មុខងារក្នុងមុខតំណែងថ្មីនេះ ស្របតាមព្រះរាជក្រឹត្យលេខ នស/រកត/១២០១/៤៥០ ចុះថ្ងៃទី០១ ខែ ធ្នូ ឆ្នាំ២០០១ ស្តីពីបៀវត្សមូលដ្ឋាន និងប្រាក់បន្ទាប់បន្សំ នៃបៀវត្សរបស់មន្ត្រីរាជការស៊ីវិល ។ ក្នុងរយៈពេលបំពេញភារកិច្ចថ្មីនេះ សាមីខ្លួនត្រូវដាក់ពាក្យសុំស្ថិតនៅក្រៅក្របខ័ណ្ឌដើម ។

**មាត្រា ៣ :** បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៤ :** រដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ ថ្ងៃទី [illegible] ឆ្នាំ២០០៦*

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី (ដើម្បីជូនជ្រាប)*
- *ដូចមាត្រា ៤ (ដើម្បីអនុវត្ត)*
- *ឯកសារ កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ៨៦៩ . អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការតម្លើងឋានន្តរស័ក្តិនាយនគរបាលជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត /០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## ស ម្រេ ច

**មាត្រា ១ :** ត្រូវបានតម្លើងឋានន្តរស័ក្តិថ្នាក់ **ឧត្តមសេនីយ៍ត្រី** ជូននាយនគរបាលជាតិជាន់ខ្ពស់ នៃអគ្គស្នងការដ្ឋាននគរបាលជាតិ ក្រសួងមហាផ្ទៃ ដូចមានរាយនាមខាងក្រោម :

១- លោកវរសេនីយ៍ទោ តើន សរុន អត្តលេខ ០៦៦៣

២- លោកវរសេនីយ៍ទោ សោម ចន្ធូ អត្តលេខ ០៩៨២

៣- លោកវរសេនីយ៍ទោ ម៉ុន សុធី អត្តលេខ ០១៣៩៨

៤- លោកវរសេនីយ៍ទោ ឌី ឡា អត្តលេខ ០២១៣២ ។

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង-ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនត្រូវអនុវត្តតាមអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ. ថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ២០០៦

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

*កន្លែងទទួល :*
- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ២*
- *ឯកសារ-កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ៤៧០ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយសហមេត្រី

៣៧

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ អគ្គមេបញ្ជាការកងយោធពលខេមរភូមិន្ទ

## សម្រេច

**មាត្រា១:** ត្រូវបានបំពាក់ **មេដាយសហមេត្រី** ថ្នាក់ **ធិបឌិន្ទ** ជូនចំពោះឯកឧត្តម ឧត្តមសេនីយ៍ទោ **SYIFUL RIZAL** មេបញ្ជាការកងទ័ពពិសេស នៃសាធារណរដ្ឋឥណ្ឌូណេស៊ី ដែលមានស្នាដៃល្អក្នុងការធ្វើសហប្រតិបត្តិការ ជាមួយកងទ័ពពិសេសឆ័ត្រយោង ៩១១ នៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ និង អគ្គមេបញ្ជាការកងយោធពលខេមរភូមិន្ទ ត្រូវអនុវត្ត អនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០០៦

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច ✓
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ៤៧១ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយសហមេត្រី

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃ គណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស / រកត / ១០៩៥ / ០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃ ព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ រដ្ឋមន្ត្រី ក្រសួងការពារជាតិ

### សម្រេច

**មាត្រា១** : ត្រូវបានបំពាក់ **មេដាយសហមេត្រី ថ្នាក់ធិបឌិន្ទ** ជូន អង្គការ អ៊ីយូ អាសាក់ (EU/ASAC) សហភាពអឺរ៉ុប ដែលមានស្នាដៃល្អ ក្នុងកិច្ចសហប្រតិបត្តិការ ជួយទប់ស្កាត់ និងទុកដាក់អាវុធជាតិផ្ទុះ ប្រកបដោយសុវត្ថិភាពល្អ នៅព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា២** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង រដ្ឋមន្ត្រី ក្រសួងការពារជាតិ ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ,ថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០០៦

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល** :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ:...៤២៧ អនក្រ.បក...

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយការងារ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាស អោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃ គណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស / រកត / ១០៩៥ / ០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពី ការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃ ព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ រដ្ឋមន្ត្រី ក្រសួងការពារជាតិ

## សម្រេច

**មាត្រា១** : ត្រូវបានបំពាក់ **មេដាយការងារ** តាមលំដាប់ថ្នាក់ ជូន នាយទាហាន និង មន្ត្រី អ៊ីយូ អាសាក់ (EU/ASAC) ដែលមានស្នាដៃល្អ ក្នុងកិច្ចសហប្រតិបត្តិការ ជួយទប់ស្កាត់ និងទុកដាក់អាវុធជាតិផ្ទុះ ដូចមានរាយនាមខាងក្រោម :

### ក- មេដាយមាសការងារ :

១- ឧត្តមសេនីយ៍ត្រី **ហង្ស សំអន** អត្តលេខ ០០០៥៧៤ នាយករង នាយកដ្ឋានបំពាក់សំភារៈសឹក អគ្គនាយកដ្ឋាន សំភារៈបច្ចេកទេស ក្រសួងការពារជាតិ

២- វរសេនីយ៍ឯក **ឃុត ស៊ិនហេង** អត្តលេខ ០០២១៩៨ នាយករងទីចាត់ការបច្ចេកទេស អគ្គបញ្ជាការដ្ឋាន

៣- វរសេនីយ៍ឯក **ទឹម សំអូន** អត្តលេខ ០០៩៥៩៥ នាយលេខាធិការដ្ឋាន នាយកដ្ឋានបំពាក់សំភារៈសឹក អគ្គនាយកដ្ឋានសំភារៈបច្ចេកទេស ក្រសួងការពារជាតិ

៤- វរសេនីយ៍ឯក **យិន សាធ** អត្តលេខ ០០១៩៧៦ នាយការិយាល័យគ្រាប់ ទីចាត់ការចលនូបត្ថម្ភ អគ្គបញ្ជាការដ្ឋាន

៥- វរសេនីយ៍ឯក **ខាន់ ម៉ិនធឿន** អត្តលេខ ០០១៥៦៧ នាយការិយាល័យសព្វាវុធ នាយកដ្ឋានបច្ចេកទេស អគ្គនាយកដ្ឋានសំភារៈបច្ចេកទេស ក្រសួងការពារជាតិ

៦- វរសេនីយ៍ឯក **អ៊ឹម អាន** អត្តលេខ ០០៣២៤៩ នាយការិយាល័យគ្រប់គ្រងគ្រឿងបំពាក់សំភារៈសឹក នាយកដ្ឋាន បំពាក់សំភារៈសឹក អគ្គនាយកដ្ឋានសំភារៈបច្ចេកទេស ក្រសួងការពារជាតិ

៧- វរសេនីយ៍ទោ **ស្វាយ ហេង** អត្តលេខ ០០៨៩៦២ នាយកស្តុភារ ហិរញ្ញវត្ថុ នាយកដ្ឋានបំពាក់សំភារៈសឹក អគ្គនាយកដ្ឋានសំភារៈបច្ចេកទេស ក្រសួងការពារជាតិ

៨- វរសេនីយ៍ទោ **ចន្ទន៍ ពិសិដ្ឋ** អត្តលេខ ០០១៨៣០ នាយរងលេខាធិការដ្ឋាន អគ្គនាយកដ្ឋានសំភារៈបច្ចេកទេសក្រសួងការពារជាតិ

៩- លោក ណែត សុថៃ បុគ្គលិកបកប្រែ អ៊ីយូ អាសាក់ (EU/ASAC)

១០- លោក ចាន់ ម៉ុនធឿន មន្ត្រីរដ្ឋបាល និងហិរញ្ញវត្ថុ អ៊ីយូ អាសាក់ (EU/ASAC)

**ខ- មេដាយប្រាក់ការងារ :**

១- វរសេនីយ៍ត្រី រស់ សឿន អត្តលេខ ០១៧២៧៩ នាយរងលេខាធិការដ្ឋាន នាយកដ្ឋានបំពាក់សំភារៈសឹក អគ្គនាយកដ្ឋានសំភារៈបច្ចេកទេស ក្រសួងការពារជាតិ

២- វរសេនីយ៍ត្រី សុខ ម៉ៅសាយ អត្តលេខ ០៣២២៥៣ នាយរងលេខាធិការដ្ឋាន នាយកដ្ឋានបំពាក់សំភារៈសឹក អគ្គនាយកដ្ឋានសំភារៈបច្ចេកទេស ក្រសួងការពារជាតិ

៣- វរសេនីយ៍ត្រី សួន គឹមអឿន អត្តលេខ ០២៣៨៤៥ ជំនួយការការិយាល័យគ្រប់គ្រងគ្រឿងបំពាក់សំភារៈសឹក នាយកដ្ឋានបំពាក់សំភារៈសឹក អគ្គនាយកដ្ឋានសំភារៈបច្ចេកទេស ក្រសួងការពារជាតិ

៤- វរសេនីយ៍ត្រី ទឹម រតនា អត្តលេខ ០៣១៣៩០ នាយផ្នែករបៀប នាយកដ្ឋានបំពាក់សំភារៈសឹក អគ្គនាយកដ្ឋានសំភារៈបច្ចេកទេស ក្រសួងការពារជាតិ

**គ- មេដាយសំរិទ្ធការងារ :**

១- កញ្ញា អាត់ សុណា លេខាធិការ នាយកគំរោង អ៊ីយូ អាសាក់ (EU/ASAC)

២- លោក ម៉ាត់ មុនីរដ្ឋ ជំនួយការការិយាល័យ អ៊ីយូ អាសាក់ (EU/ASAC)

៣- លោក ត្រី ដារ៉ូច ជំនួយការការិយាល័យ និងអ្នកបច្ចេកទេសកំទេចអាវុធ អ៊ីយូ អាសាក់ (EU/ASAC)

៤- អ្នកស្រី ជន ពិសី បុគ្គលិកបកប្រែ អ៊ីយូ អាសាក់ (EU/ASAC)

៥- កញ្ញា សៀក បុប្ផា ជំនួយការមន្ត្រីរដ្ឋបាល និង ហិរញ្ញវត្ថុ អ៊ីយូ អាសាក់ (EU/ASAC)

**មាត្រា២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង រដ្ឋមន្ត្រី ក្រសួងការពារជាតិ ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ,ថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០០៦

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

- -ក្រសួងព្រះបរមរាជវាំង
- -អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- -អគ្គលេខាធិការដ្ឋានរដ្ឋសភា
- -អគ្គលេខាធិការរាជរដ្ឋាភិបាល
- -ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- -ដូចក្នុងមាត្រា ១ និង មាត្រា ២
- -រាជកិច្ច
- -ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៤៧៣ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ

៙ ៚

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងការពារជាតិ

## សម្រេច

**មាត្រា ១ :** ត្រូវបានចំពាក់ **មេដាយមុនីសារាភ័ណ្ឌ** តាមលំដាប់ថ្នាក់ ជូនកងឯកភាព និង នាយទាហានជាន់ខ្ពស់ ដែលមានស្នាដៃក្នុងកិច្ចសហប្រតិបត្តិការ ជាមួយអ៊ឺយូ អាសាក់ (EU/ASAC) អនុវត្តគំរោង លើការរក្សាបញ្ជី និងទុកដាក់អាវុធ ប្រកបដោយសុវត្ថិភាពល្អ ក្នុងកងយោធពលខេមរភូមិន្ទ ដូចមានរាយនាមខាងក្រោម :-

**ក_មេដាយមុនីសារាភ័ណ្ឌថ្នាក់ធិបឌិន្ទ :**

**_ចំពោះបុគ្គល**

| | | | | |
|---|---|---|---|---|
| ១-នាយឧត្តមសេនីយ៍ | **មាស** | **សុភា** | អត្តលេខ ០០០០១៦ | អគ្គមេបញ្ជាការរង និងជាមេបញ្ជាការ កងទ័ពជើងគោក |
| ២-ឧត្តមសេនីយ៍ឯក | **គន់** | **គីម** | អត្តលេខ ០០៤២៨២ | អគ្គមេបញ្ជាការរង កងយោធពលខេមរភូមិន្ទ |
| ៣-ឧត្តមសេនីយ៍ឯក | **សំ** | **ចន្ទ្រាឌន** | អត្តលេខ ០០០២០៥ | អគ្គលេខាធិការ ក្រសួងការពារជាតិ |
| ៤-ឧត្តមសេនីយ៍ឯក | **ទៅ** | **តិរុណា** | អត្តលេខ ០០០០៧៥ | អគ្គនាយក អគ្គនាយកដ្ឋានសំភារៈបច្ចេកទេស ក្រសួងការពារជាតិ |

៥-ឧត្តមសេនីយ៍ឯក **ស៊ុំ សំណាង** អត្តលេខ ០០០០៧៤ អគ្គនាយក អគ្គនាយកដ្ឋាន ភស្តុភារ-ហិរញ្ញវត្ថុ ក្រសួងការពារជាតិ

៦-ឧត្តមសេនីយ៍ឯក **មាស សាវ័ន** អត្តលេខ ០០០០៧៩ អគ្គនាយក អគ្គនាយកដ្ឋាន យោធសេវា ក្រសួងការពារជាតិ

៧-ឧត្តមសេនីយ៍ឯក **សៅ សុខា** អត្តលេខ ០០០១០៥ មេបញ្ជាការ កងរាជអាវុធហត្ថ

៨-ឧត្តមសេនីយ៍ឯក **សឹង សំណាង** អត្តលេខ ០០០១០១ មេបញ្ជាការ កងទ័ពជើងអាកាស

៩-ឧត្តមសេនីយ៍ឯក **មាស សំអុល** អត្តលេខ ០០០២១១ នាយក នាយកដ្ឋានបុគ្គលិក ក្រសួងការពារជាតិ

១០-ឧត្តមនាវីឯក **អ៊ុង សំខាន់** អត្តលេខ ០០០០៤២ មេបញ្ជាការ កងទ័ពជើងទឹក

១១-ឧត្តមសេនីយ៍ឯក **ម៉ីក់ សារុន** អត្តលេខ ០០០០៩១ នាយរងសេនាធិការចំរុះ និងជា នាយកទីចាត់ការចលនូបត្ថម្ភ អគ្គបញ្ជាការដ្ឋាន

១២-ឧត្តមសេនីយ៍ឯក **ជា សារិន** អត្តលេខ ០០០០៩០ មេបញ្ជាការរង និងជា នាយសេនាធិការ កងទ័ពជើងគោក

១៣-ឧត្តមសេនីយ៍ឯក **ឡៀ សុទ្ធ** អត្តលេខ ០០០២២៩ អគ្គនាយករង អគ្គនាយកដ្ឋាន សំភារៈបច្ចេកទេស ក្រសួងការពារជាតិ

១៤-ឧត្តមសេនីយ៍ឯក **ឈូ ឆាន់** អត្តលេខ ០០០២២៨ អគ្គនាយករង អគ្គនាយកដ្ឋាន សំភារៈបច្ចេកទេស ក្រសួងការពារជាតិ

១៥-ឧត្តមសេនីយ៍ទោ **សុន គីមស៊ីន** អត្តលេខ ០០០៤៩៦ នាយក នាយកដ្ឋានបំពាក់សំភារៈសឹក អគ្គនាយកដ្ឋានសំភារៈបច្ចេកទេស ក្រសួងការពារជាតិ

១៦-ឧត្តមសេនីយ៍ទោ **រស់ ឆោម** អត្តលេខ ០០១១៦៧ អគ្គលេខាធិការរង ក្រសួងការពារជាតិ

១៧-ឧត្តមសេនីយ៍ទោ **លី គុសល** អត្តលេខ ០០៤៣៧៤ នាយក នាយកដ្ឋានហិរញ្ញវត្ថុ អគ្គនាយកដ្ឋានភស្តុភារ-ហិរញ្ញវត្ថុ ក្រសួងការពារជាតិ

**ខ-មេដាយមុនីសារាភ័ណ្ឌថ្នាក់សេនា :**

**-ចំពោះកងឯកភាព**

១-អគ្គលេខាធិការដ្ឋាន ក្រសួងការពារជាតិ

២-អគ្គនាយកដ្ឋានសំភារៈបច្ចេកទេស ក្រសួងការពារជាតិ

៣-អគ្គនាយកដ្ឋានយោធសេវា ក្រសួងការពារជាតិ

៤-អគ្គនាយកដ្ឋានភស្តុភារ-ហិរញ្ញវត្ថុ ក្រសួងការពារជាតិ

៥-នាយកដ្ឋានបុគ្គលិក ក្រសួងការពារជាតិ

៦-នាយកដ្ឋានបំពាក់សំភារៈសឹក អគ្គនាយកដ្ឋានសំភារៈបច្ចេកទេស ក្រសួងការពារជាតិ

៧-ទីចាត់ការចលនូបត្ថម្ភ អគ្គបញ្ជាការដ្ឋាន

៨-ទីចាត់ការបច្ចេកទេស អគ្គបញ្ជាការដ្ឋាន

៩-បញ្ជាការដ្ឋាន កងទ័ពជើងគោក

១០-បញ្ជាការដ្ឋាន កងទ័ពជើងទឹក

១១-បញ្ជាការដ្ឋាន កងទ័ពជើងអាកាស

១២-បញ្ជាការដ្ឋាន កងរាជអាវុធហត្ថលើផ្ទៃប្រទេស

១៣-យោធភូមិភាគទី ១

១៤-យោធភូមិភាគទី ២

១៥-យោធភូមិភាគទី ៣

១៦-យោធភូមិភាគទី ៤

១៧-យោធភូមិភាគទី ៥

១៨-យោធភូមិភាគពិសេស

១៩-កងពលធំអន្តរាគមន៍លេខ ២

**-ចំពោះបុគ្គល**

១-ឧត្តមសេនីយ៍ទោ **យ៉ាំល់ ពិសិដ្ឋ** អត្តលេខ ០០០៣២៨ នាយក ទីចាត់ការបច្ចេកទេស អគ្គបញ្ជាការដ្ឋាន

២-ឧត្តមសេនីយ៍ទោ **អ៊ុយ សុធារា** អត្តលេខ ០០០១៤០ មេបញ្ជាការ កងពលធំអន្តរាគមន៍លេខ ២

៣-ឧត្តមសេនីយ៍ត្រី **កែន នារា** អត្តលេខ ០០០៦៧៤ នាយកការិយាល័យទី៤ កងទ័ពជើងគោក

៤-ឧត្តមសេនីយ៍ត្រី **ម៉ែន យន់** អត្តលេខ ០០១២១៤ នាយករង នាយកដ្ឋានបំពាក់ សំភារៈសឹក អគ្គនាយកដ្ឋានសំភារៈបច្ចេកទេស ក្រសួងការពារជាតិ

**មាត្រា ២ :** រដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង រដមន្ត្រីក្រសួងការពារជាតិ ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ២០០៦

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**<u>កន្លែងទទួល</u> :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា១ និងមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

**រាជរដ្ឋាភិបាលកម្ពុជា** **ជាតិ សាសនា ព្រះមហាក្សត្រ**

**លេខ:** ៤៤៤ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពី
## ការតែងតាំងមន្ត្រីរាជការ

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១០ អនក្រ.បក ចុះថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៦៣ អនក្រ.បក ចុះថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០០៣ ស្តីពីការគ្រប់គ្រងការអនុវត្តន៍ ការផ្លាស់ប្តូរក្របខណ្ឌ ឋានន្តរស័ក្តិ និងថ្នាក់របស់មន្ត្រីរាជការស៊ីវិល
- យោងតាមសំណើរបស់ប្រធានគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា

### ស ម្រេ ច

**មាត្រា ១ :** ត្រូវបានប្រគល់ភារកិច្ចជូនមន្ត្រីរាជការចំនួន ០២រូប នៃគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា អោយបំពេញមុខងារដូចតទៅ :

១-លោក **វ៉ាត់ បុត្តក្ញុសល** ជា ប្រធាននាយកដ្ឋានផែនការ ។

២-លោក **សូ សុភ័ន្ទ** ជា ប្រធាននាយកដ្ឋានបណ្តុះបណ្តាល ។

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ប្រធានគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង-ស្ថាប័ន ដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ អោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ មិថុនា ឆ្នាំ ២០០៦

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៤៧៥ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការតែងតាំងក្រុមប្រឹក្សាភិបាល នៃ រដ្ឋាករទឹកស្វយ័ត ក្រុងភ្នំពេញ អាណត្តិទី ៣

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៦៩៦/០៣ ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៥២ អនក្រ.បក ចុះថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ
- បានឃើញអនុក្រឹត្យលេខ ៣៤ អនក្រ.បក ចុះថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ ២០០០ ស្តីពីការកែសម្រួលអនុក្រឹត្យលេខ ៥២ អនក្រ.បក ស្តីពីការបង្កើតរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ
- បានឃើញអនុក្រឹត្យលេខ ១៤ អនក្រ.បក ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ២០០៤ ស្តីពីការផ្ទេររដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ អោយស្ថិតនៅក្រោមអាណាព្យាបាលនៃក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

## សម្រេច

**មាត្រា ១** : តែងតាំងក្រុមប្រឹក្សាភិបាលនៃរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ អាណត្តិទី ៣ ដែលមានសមាសភាព ដូចខាងក្រោម ៖

| | | | |
|---|---|---|---|
| ១_ឯកឧត្តម | **ឌួន នៅ** | តំណាង ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល | ប្រធាន |
| ២_ឯកឧត្តម | **អ៊ឹម ខេង** | តំណាង ទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ៣_ឯកឧត្តម | **ឯក សុនចាន់** | អគ្គនាយករដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ | សមាជិក |

| | | | |
|---|---|---|---|
| ៤_ឯកឧត្តម | **ជូ ចិជិត្ត** | តំណាង ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ | សមាជិក |
| ៥_ឯកឧត្តម | **ម៉ាន់ ឈឿន** | តំណាង សាលាក្រុងភ្នំពេញ | សមាជិក |
| ៦_លោក | **ហុង ស៊ីលីន** | តំណាង ក្រសួងមហាផ្ទៃ | សមាជិក |
| ៧_លោក | **សែម ប៊ុនហេង** | តំណាង និយោជិតរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ | សមាជិក |

មាត្រា ២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ និង សាមីខ្លួនដូចមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ៕

*រាជធានីភ្នំពេញ, ថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០០៦*

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល**

*ក្រសួងព្រះបរមរាជវាំង*
*អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
*អគ្គលេខាធិការដ្ឋានរដ្ឋសភា*
*អគ្គលេខាធិការរាជរដ្ឋាភិបាល*
*ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
*រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ*
*ដូចមាត្រា ២*
*ឯកសារ_កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ...៤៧៦...អនក្រ.តត

# អនុក្រឹត្យ

## ស្តីពី

## ការតែងតាំងសមាសភាពក្រុមប្រឹក្សាភិបាលកំពង់ផែស្វយ័តក្រុងព្រះសីហនុ

---

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២៩៧/៩១ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៧ ស្តីពីលក្ខន្តិកៈគតិយុត្តនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ ៣៧៤ អនក្រ ចុះថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ២០០៣ ស្តីពីការតែងតាំងសមាសភាពក្រុមប្រឹក្សាភិបាលកំពង់ផែស្វយ័តក្រុងព្រះសីហនុ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន

## ស ម្រេ ច

**មាត្រា ១ :** តែងតាំងក្រុមប្រឹក្សាភិបាលកំពង់ផែស្វយ័តក្រុងព្រះសីហនុ នៅក្នុងអាណត្តិទី ៣ បន្តមួយអាណត្តិទៀត ដែលមានសមាសភាព ដូចខាងក្រោម :

- ឯកឧត្តម **លូ គីមឈុន** អគ្គនាយក កំពង់ផែស្វយ័តក្រុងព្រះសីហនុ ប្រធាន
- ឯកឧត្តម **ហ៊ី អានវ៉ានិថ** តំណាង ក្រសួងសាធារណការ និងដឹកជញ្ជូន សមាជិក

- ឯកឧត្តម **វង្សី វិស្សុត** តំណាង ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សមាជិក
- ឯកឧត្តម **សាយ ហាក់** តំណាង អាជ្ញាធរក្រុងព្រះសីហនុ សមាជិក
- លោក **តឹករ៉េត សំរេច** តំណាង ទីស្តីការគណៈរដ្ឋមន្ត្រី សមាជិក
- លោក **ចម បូរិទ្ធ** តំណាង ក្រសួងពាណិជ្ជកម្ម សមាជិក

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ, ថ្ងៃទី១៥ ខែឧសភា ឆ្នាំ ២០០៦*

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

*កន្លែងទទួល :*

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- ***ដូចមាត្រា ២***
- *ឯកសារ-កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ធនាគារជាតិ នៃ កម្ពុជា**

លេខ ធ៧-០៦-០៧៣ ប្រ.ក

លិខិតចូល
ថ្ងៃទី 15 ខែ 6 ឆ្នាំ2006

# ប្រកាស

## ស្តីពី

## ការប្រើប្រាស់ និងការការពារព័ត៌មានឥណទាន

**ទេសាភិបាល ធនាគារជាតិនៃកម្ពុជា**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៧ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១៩៩/១៣ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៤/២៤៤ ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០០៤ ស្តីពីការតែងតាំងឯកឧត្តម **ជា ចាន់តូ** ជាអគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា មានឋានៈស្មើទេសរដ្ឋមន្ត្រី
- យោងតាមស្មារតីអង្គប្រជុំថ្នាក់ដឹកនាំធនាគារជាតិនៃកម្ពុជា ថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០០៦

# ស ំ រេ ច

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**ប្រការ ១.-**

ប្រកាសនេះមានគោលបំណងលើកស្ទួយឱ្យបានរឹងមាំនូវសកម្មភាពឥណទាន និងការគ្រប់គ្រងហានិភ័យរបស់គ្រឹះស្ថានទាំងអស់ ដែលចូលរួមនៅក្នុងប្រព័ន្ធហិរញ្ញវត្ថុដោយមានការអនុញ្ញាតឱ្យបង្កើតភ្នាក់ងារដែលប្រមូល និង

ចែករំលែកព័ត៌មានឥណទានអវិជ្ជមានទាក់ទងនឹងអ្នកខ្ចីប្រាក់ធនាគារ ក្នុងចំណោមធនាគារជាសមាជិក និងដោយមានការការពារការសំងាត់របស់អ្នកខ្ចីប្រាក់ មិនឱ្យប្រើប្រាស់ខុសគោលដៅ និងជៀសវាងការរំលោភលើព័ត៌មានឥណទាន ។

**ប្រការ ២.-**

ពាក្យបច្ចេកទេសមួយចំនួនដែលប្រើក្នុងប្រកាសនេះ មាននិយមន័យដូចតទៅ ÷

**"ច្បាប់ធនាគារ"** គឺច្បាប់ស្តីពីគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ។

**"ច្បាប់ធនាគារកណ្តាល"** គឺច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា ។

**"ព័ត៌មានឥណទាន"** គឺជាព័ត៌មានស្តីពីអ្នកដែលបានខ្ចីប្រាក់ឥណទាន ឬជាព័ត៌មានចាំបាច់សំរាប់កំណត់អត្តសញ្ញាណ និងវាយតម្លៃភាពគួរទុកចិត្តបាននៃអ្នកខ្ចីប្រាក់ ។

**"ទីភ្នាក់ងារប្រមូលព័ត៌មានឥណទានមជ្ឈការ"** ហៅកាត់ថា **"ភ្នាក់ងារ"** គឺជាស្ថាប័នដែលប្រមូល និងផ្សព្វផ្សាយព័ត៌មានឥណទាន ព្រមទាំងគ្រប់គ្រងប្រព័ន្ធចែករំលែកព័ត៌មានឥណទាន ។

**"ប្រព័ន្ធចែករំលែកព័ត៌មានឥណទាន"** រួមមានសូហ្វវែរ ហាដវែរ និងអភិបាលកិច្ចចាំបាច់សំរាប់ឱ្យភ្នាក់ងារដំណើរការប្រចាំថ្ងៃ ។

**"ធនាគារជាសមាជិក"** គឺជាធនាគារ ដែលត្រូវបានបង្កើតឡើងតាមច្បាប់ធនាគារនៃព្រះរាជាណាចក្រកម្ពុជា និងតាមបទបញ្ញាផ្សេងៗទៀត ផ្តល់មធ្យោបាយឥណទានឱ្យអ្នកខ្ចីប្រាក់ និងចុះហត្ថលេខាលើក្រមប្រតិបត្តិ ដើម្បីបញ្ជូនព័ត៌មានឥណទានទៅឱ្យភ្នាក់ងារ ។

**"អ្នកចូលរួមផ្សេងទៀត"** គឺជាបុគ្គល អង្គភាព និងគ្រឹះស្ថានហិរញ្ញវត្ថុក្រៅពីធនាគារដែលមានបំណងចូលរួមក្នុងប្រព័ន្ធចែករំលែកព័ត៌មានឥណទាន ហើយដែលបានទទួលការអនុម័តឱ្យចូលរួមពីធនាគារជាតិនៃកម្ពុជា ។

**"មធ្យោបាយឥណទាន"** គឺជាកម្ចី ឬប្រភេទឥណទានណាផ្សេងទៀតដែលគ្រឹះស្ថានហិរញ្ញវត្ថុផ្តល់ទៅឱ្យអ្នកខ្ចីប្រាក់ ។

**"អ្នកខ្ចីប្រាក់"** គឺជាឯកត្តបុគ្គល ឬអង្គភាពអាជីវកម្មដែលបានទទួលមធ្យោបាយឥណទាន ។

**"ព័ត៌មានសំគាល់អត្តសញ្ញាណ"** គឺជាព័ត៌មានចាំបាច់សំរាប់វាយតំលៃអត្តសញ្ញាណត្រឹមត្រូវរបស់ឯកត្តបុគ្គល ឬរបស់អង្គភាពអាជីវកម្ម ។

**"ព័ត៌មានឥណទានអវិជ្ជមាន"** គឺជាព័ត៌មានស្តីពីឥណទានហួសកាលកំណត់ (ហួសកាលកំណត់ច្រើនជាង ៩០ថ្ងៃ) រួមមានប្រាក់ដើម ការប្រាក់ និងប្រាក់ជំពាក់លើគណនីឥណទានវិបារូបន៍ ដូចមានចែងនៅក្នុងក្រមប្រតិបត្តិ ។

**"បំណុលកកស្ទះ"** គឺជាឥណទានហួសកាលកំណត់សងច្រើនជាង៩០ថ្ងៃ ដូចមានចែងនៅក្នុងចំណុចទី ១៨ ឧបសម្ព័ន្ធទី៤ (និយមន័យនៃបច្ចេកស័ព្ទ និងប៉ារ៉ាមែត្រនានាដែលបានប្រើក្នុងប្រព័ន្ធចែករំលែកព័ត៌មានឥណទាន ) នៃក្រមប្រតិបត្តិ ។

**"ការខកខានមិនបានសង"** គឺជាមូលប្បទានប័ត្រដែលបានបង្វិលមកវិញ ឬរូបិយាណត្តិដែលមិនត្រូវបានទូទាត់ដោយសារមានមូលនិធិមិនគ្រប់គ្រាន់ ឬគ្មានមូលនិធិ ឬមានមូលហេតុផ្សេងពីនេះ ដូចមានបញ្ជាក់នៅចំណុចទី ១៨ ក្នុងឧបសម្ព័ន្ធទី៤ នៃក្រមប្រតិបត្តិ ។

**ប្រការ ៣.-**

១- ធនាគារដែលត្រូវបានបង្កើតឡើងតាមច្បាប់ធនាគារនិងតាមបទបញ្ញាផ្សេងទៀត ហើយដែលមានបំណងចូលរួមនៅក្នុងប្រព័ន្ធចែករំលែកព័ត៌មានឥណទាន ត្រូវចុះហត្ថលេខាលើក្រមប្រតិបត្តិជាមួយធនាគារជាតិនៃកម្ពុជា ។

២- ក្រមប្រតិបត្តិដែលពណ៌នាអំពីការប្រមូល ការផ្សព្វផ្សាយ ការគ្រប់គ្រង និងការប្រើប្រាស់ព័ត៌មានឥណទាន ត្រូវបានរៀបចំ និងពង្រឹងការអនុវត្តដោយធនាគារជាតិនៃកម្ពុជា ។

៣- ខ្លឹមសារ និងលក្ខខណ្ឌនៃក្រមប្រតិបត្តិ អាចត្រូវបានកែសំរួលតាមតម្រូវការជាក់ស្តែងតាមការកំណត់របស់ធនាគារជាតិនៃកម្ពុជា ឬដោយមានកិច្ចព្រមព្រៀងពីគណៈកម្មាធិការគ្រប់គ្រងប្រព័ន្ធចែករំលែកព័ត៌មានឥណទាន ។

៤- បុគ្គលក្រៅពីធនាគារដែលមានបំណងចូលរួមក្នុងប្រព័ន្ធចែករំលែកព័ត៌មានឥណទាន អាចដាក់ពាក្យសុំមកធនាគារជាតិនៃកម្ពុជា ។

**ប្រការ ៤.-**

ធនាគារជាតិនៃកម្ពុជាត្រូវតែងតាំងប្រធានក្រុមប្រឹក្សាភិបាលនៃភ្នាក់ងារ តទៅហៅថា **"ក្រុមប្រឹក្សាភិបាលនៃប្រព័ន្ធចែករំលែកព័ត៌មានឥណទាន"** ដែលជាអ្នកទទួលខុសត្រូវលើប្រតិបត្តិការនៃភ្នាក់ងារនេះ ។ ប្រធានអាចប្រគល់សិទ្ធិត្រួតពិនិត្យ និងគ្រប់គ្រងកិច្ចការប្រចាំថ្ងៃឱ្យប្រធានគណៈកម្មាធិការគ្រប់គ្រង ។

## ជំពូកទី ២
## ការបង្កើតប្រព័ន្ធចែករំលែកព័ត៌មានឥណទាន

**ប្រការ ៥.-**

១- ធនាគារជាតិនៃកម្ពុជា គឺជាភ្នាក់ងារដែលចូលរួមក្នុងប្រតិបត្តិការនិងការគ្រប់គ្រងប្រព័ន្ធចែករំលែកព័ត៌មានឥណទាន ព្រមទាំងបង្កើតគោលនយោបាយផ្សេងៗ ស្តីពីប្រតិបត្តិការរបស់ប្រព័ន្ធនេះតទៅមុខ ។

២- ភ្នាក់ងារត្រូវបង្កើត និងរក្សាប្រព័ន្ធចែករំលែកព័ត៌មានឥណទានតាមទំព័រវេបសាយ ដែលតាមរយៈនេះ ធនាគារជាសមាជិក និងគ្រឹះស្ថានហិរញ្ញវត្ថុប្រតិស្រុតដទៃទៀតត្រូវរាយការណ៍ និងចែករំលែកព័ត៌មានឥណទានដែលបានធ្វើមជ្ឈការហើយ ។

៣- ភ្នាក់ងារត្រូវមានក្រុមប្រឹក្សាភិបាលរបស់ប្រព័ន្ធចែករំលែកព័ត៌មានឥណទាន គណៈកម្មាធិការគ្រប់គ្រង និងក្រុមប្រតិបត្តិការ។ ប្រធានក្រុមប្រឹក្សាភិបាលនៃប្រព័ន្ធចែករំលែកព័ត៌មានឥណទាន ត្រូវតែងតាំងនាយកពី៦ ទៅ ៨រូប មកពីភ្នាក់ងារ និងមកពីធនាគារជាសមាជិក ប្រសិនបើចាំបាច់ ។ សមាជិកនៃគណៈកម្មាធិការគ្រប់គ្រងក្រៅពីចំនួនចាំបាច់នៃអ្នកចូលរួមរបស់ភ្នាក់ងារ អាចរួមមាន តំណាងធនាគារជាសមាជិកដែលត្រូវបានស្នើឡើងដោយក្រុមប្រឹក្សាភិបាលនៃប្រព័ន្ធចែករំលែកព័ត៌មានឥណទាន តំណាងមួយរូបមកពីសមាគមធនាគារិកនៅកម្ពុជា និងអ្នកជំនាញការដែលត្រូវបានស្នើឡើងដោយក្រុមប្រឹក្សាភិបាលនៃប្រព័ន្ធចែករំលែកព័ត៌មានឥណទាន។ ក្រុមប្រតិបត្តិការរួមមាន ប្រធានដឹកនាំ និងបុគ្គលិកនៃការិយាល័យព័ត៌មានុសាស្ត្ររបស់ភ្នាក់ងារ ។

៤- ភ្នាក់ងារមានសិទ្ធិដាក់ទណ្ឌកម្ម ពិន័យ ឬព្យួរសមាជិកភាពប្រព័ន្ធចែករំលែកព័ត៌មានឥណទាន ចំពោះធនាគារជាសមាជិក និងចំពោះអ្នកចូលរួមដទៃទៀតដែលរំលោភលើក្រមប្រតិបត្តិ។

**ប្រការ ៦.-**

១- ធនាគារជាសមាជិក និងអ្នកចូលរួមដទៃទៀតនៃប្រព័ន្ធចែករំលែកព័ត៌មានឥណទាន ត្រូវបានអនុញ្ញាតឱ្យបញ្ជូនព័ត៌មានឥណទានក្នុងទំរង់ជាទិន្នន័យអេឡិចត្រូនិកជាទៀងទាត់ ដូចមានបញ្ជាក់នៅក្នុងសេចក្តីណែនាំមកកាន់ភ្នាក់ងារ ក្នុងគោលបំណងចែករំលែកព័ត៌មានឥណទាន ។

២- មន្ត្រីឬបុគ្គលិករបស់ភ្នាក់ងារនិងធនាគារជាសមាជិកដែលបានបំពេញភារកិច្ចគ្រប់គ្រង និងរាយការណ៍ព័ត៌មានឥណទានក្នុងប្រព័ន្ធចែករំលែកព័ត៌មានឥណទានដោយសុចរិតអនុលោមតាមមាត្រា ១៥ នៃច្បាប់ស្តីពីគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ស្តីពីការសម្ងាត់វិជ្ជាជីវៈ មិនត្រូវទទួលខុសត្រូវចំពោះការរំលោភលើការសម្ងាត់វិជ្ជាជីវៈឡើយ លើកលែងតែមន្ត្រី បុគ្គលិកទាំងនោះ រំលោភលើប្រការ ១៨ នៃប្រកាសនេះ ។

៣- ធនាគារជាសមាជិកមានសិទ្ធិប្រើប្រាស់ព័ត៌មានឥណទាន ដែលគ្រប់គ្រងដោយភ្នាក់ងារ និងប្រើប្រាស់ព័ត៌មានឥណទានសំរាប់គោលបំណងតែមួយគឺការវាយតម្លៃភាពគួរឱ្យជឿទុកចិត្តបាននៃអតិថិជនខ្ចីប្រាក់តែប៉ុណ្ណោះ ។

## ជំពូកទី ៣
## ការគ្រប់គ្រងព័ត៌មានឥណទាន

**ប្រការ ៧.-**

១- ភ្នាក់ងារត្រូវបង្កើតគណៈកម្មាធិការគ្រប់គ្រង សំរាប់ធ្វើសេចក្តីសំរេចចិត្តតាមកថាខ័ណ្ឌដូចមានរាយខាងក្រោមតាមរយៈការពិគ្រោះយោបល់ ។ កថាខ័ណ្ឌ ក ដល់ គ តម្រូវឱ្យមានការឯកភាពពីក្រុមប្រឹក្សាភិបាលនៃប្រព័ន្ធចែករំលែកព័ត៌មានឥណទាន មុនពេលធ្វើការសម្រេចចិត្ត ។ កថាខ័ណ្ឌ ឃ និង ង អាចត្រូវកំណត់ និងអនុវត្តដោយប្រធានគណៈកម្មាធិការគ្រប់គ្រង ប៉ុន្តែចាំបាច់ត្រូវរាយការណ៍ទៅឱ្យក្រុមប្រឹក្សាភិបាលប្រព័ន្ធចែករំលែកព័ត៌មានឥណទាន នៅពេលក្រោយមកបន្ទាប់ពីមានសេចក្តីសម្រេចចិត្ត ។

ក- ហេតុការណ៍ទាក់ទងជាមួយប្រភេទជាក់លាក់នៃព័ត៌មានឥណទាន ដែលភ្នាក់ងារត្រូវប្រមូល និងរយៈពេលរក្សាទុក ដែលត្រូវអនុវត្តតាមបទប្បញ្ញត្តិនៃច្បាប់ពាក់ព័ន្ធ ។

ខ- ហេតុការណ៍ទាក់ទងនឹងការទទួលបន្ទុក ការបែងចែក និងការទូទាត់សោហ៊ុយប្រតិបត្តិការ ដែលកើតមាននៅក្នុងដំណើរការនៃការប្រមូលផ្តុំ ការគ្រប់គ្រង និងការប្រើប្រាស់ព័ត៌មានឥណទានដោយភ្នាក់ងារ និងការវិនិយោគលើគំរោងថ្មីណាមួយ ។

គ- ហេតុការណ៍ទាក់ទងជាមួយការស្រាវជ្រាវពីលក្ខខណ្ឌជាក់ស្តែង ក្នុងការអនុវត្តតាមភារកិច្ចរបស់គ្រឹះស្ថានហិរញ្ញវត្ថុក្នុងការផ្តល់ព័ត៌មានឥណទាន និងការដាក់ទណ្ឌកម្ម និងការប្រើប្រាស់ទណ្ឌកម្ម ។

ឃ- ហេតុការណ៍ទាក់ទងនឹងវិធានការបង្ការ ក្នុងករណីមានការប្រើប្រាស់មិនត្រឹមត្រូវ និងការលេចព្ធរខ្ចាយព័ត៌មានឥណទានខុសពីអ្វីដែលមានចែងដោយច្បាប់ ។

ង- ការងារជាក់លាក់ចាំបាច់សំរាប់ប្រមូលផ្តុំការគ្រប់គ្រង និងប្រើប្រាស់ព័ត៌មានឥណទាន និងការត្រួតពិនិត្យរបស់ក្រុមប្រតិបត្តិការប្រព័ន្ធចែករំលែកព័ត៌មានឥណទាន ។

២- ប្រធានក្រុមប្រឹក្សាភិបាលនៃប្រព័ន្ធចែករំលែកព័ត៌មានឥណទាន ត្រូវតែងតាំងប្រធានគណៈកម្មាធិការគ្រប់គ្រង ។

៣- ប្រធានគណៈកម្មាធិការគ្រប់គ្រងត្រូវរៀបចំ និងត្រួតពិនិត្យក្រុមប្រតិបត្តិការចំពោះភារកិច្ចប្រចាំថ្ងៃរបស់ប្រព័ន្ធចែករំលែកព័ត៌មានឥណទាន ។ ប្រធានក្រុមប្រតិបត្តិការត្រូវទទួលការជ្រើសតាំងពីក្នុងចំណោម

បុគ្គលិកនៃការិយាល័យព័ត៌មានុសាស្ត្រ និងទទួលការតែងតាំងដោយប្រធានក្រុមប្រឹក្សាភិបាលនៃប្រព័ន្ធចែករំលែកព័ត៌មានឥណទាន ។

**ប្រការ ៨.-**

១- ភ្នាក់ងារគប្បីគ្រប់គ្រងព័ត៌មានឥណទាន ដោយធ្វើយ៉ាងណាឱ្យព័ត៌មាននោះជាព័ត៌មានត្រឹមត្រូវ និងមានបច្ចុប្បន្នភាព ។

២- ព័ត៌មានឥណទានហួសសម័យដែលលើសពីរយៈពេលត្រូវរក្សាទុក ហើយដែលអាចបង្កលក្ខណៈមិនអំណោយផលចំពោះអតិថិជន ត្រូវតែបានដកចេញពីប្រព័ន្ធចែករំលែកព័ត៌មានឥណទាន ។

**ប្រការ ៩.-**

ភ្នាក់ងារត្រូវអនុវត្តវិធានការសុវត្ថិភាពបច្ចេកទេសនិងរូបវ័ន្តចាំបាច់ ដើម្បីការពារព័ត៌មានឥណទានមិនឱ្យតតិយជនអាចចូលមកយកព័ត៌មានដោយគ្មានការអនុញ្ញាត មិនឱ្យបាត់បង់ មិនឱ្យកែប្រែខុសលំនាំដើម មិនឱ្យខូចខាតឬបំផ្លិចបំផ្លាញព័ត៌មានឥណទាន និងមិនឱ្យមានការគំរាមកំហែងមកពីខាងក្រៅចំពោះបណ្តាញនេះ ។

**ប្រការ ១០.-**

ភ្នាក់ងារត្រូវរៀបចំសេចក្តីណែនាំស្តីពីការគ្រប់គ្រង ដែលបង្ហាញឱ្យច្បាស់នូវនីតិវិធីផ្ទៃក្នុងសំរាប់ប្រមូលគ្រប់គ្រង និងប្រើប្រាស់ព័ត៌មានឥណទាន ។

## ជំពូកទី ៤

## ការការពារព័ត៌មានឥណទានរបស់អ្នកខ្ចីប្រាក់

**ប្រការ ១១.-**

ភ្នាក់ងារត្រូវបើកចំហជាសាធារណៈនូវការងារទាក់ទងនឹងប្រភេទព័ត៌មានឥណទាន ដែលត្រូវប្រមូល ផ្សព្វផ្សាយ គ្រប់គ្រងនិងប្រើប្រាស់ គោលបំណងនៃការគ្រប់គ្រងព័ត៌មានឥណទាន អ្នកទទួលព័ត៌មានឥណទាន និងសិទ្ធិរបស់អ្នកខ្ចីប្រាក់ទាក់ទងនឹងបញ្ហានេះ ។

**ប្រការ ១២.-**

ក្នុងករណីដែលធនាគារជាសមាជិកនីមួយៗមានបំណងផ្តល់ព័ត៌មានឥណទាននីមួយៗតាមចំណុចនានា ដូចមានរាយខាងក្រោម មកកាន់ភ្នាក់ងារ ធនាគារនោះត្រូវទទួលការយល់ព្រមជាលាយលក្ខណ៍អក្សរពីសំណាក់សាមីខ្លួននោះដោយប្រើគំរូបង្ហាញនៅក្នុងឧបសម្ព័ន្ធទី ២ នៃប្រកាសនេះ ។

ក- បំណុលនៅជំពាក់

ខ- បញ្ជាក់ព័ត៌មាននានាដូចជាឈ្មោះរបស់បុគ្គល អាសយដ្ឋាន លេខអត្តសញ្ញាណប័ណ្ណ ក្នុងករណីជាជនបរទេស ត្រូវបញ្ជាក់លេខអត្តសញ្ញាណប័ណ្ណបរទេសបណ្តោះអាសន្ន យោងតាមលេខរបស់លិខិត ឆ្លងដែន ភេទនិង កាលបរិច្ឆេទកំណើត និងសញ្ជាតិ

គ- ចំណុចជាក់លាក់ដូចមានចែងក្នុងក្រមប្រតិបត្តិ ។

**ប្រការ ១៣.-**

ធនាគារជាសមាជិកត្រូវជូនដំណឹងចំពោះអ្នកខ្ចីប្រាក់មុនពេលរាយការណ៍ព័ត៌មានឥណទានអវិជ្ជមានរបស់អ្នកខ្ចីប្រាក់ទៅកាន់ភ្នាក់ងារ ហើយរក្សាទុកនូវកំណត់ត្រាគំរូជូនដំណឹងដល់អ្នកខ្ចីប្រាក់តាមឧបសម្ព័ន្ធទី៤ នៃប្រកាសនេះ ។

**ប្រការ ១៤.-**

ព័ត៌មានឥណទាននីមួយៗនឹងត្រូវផ្តល់ ហើយប្រើប្រាស់សំរាប់តែវាយតម្លៃទំនុកចិត្តលើអ្នកខ្ចីប្រាក់ និងសម្រាប់វិនិច្ឆ័យថាតើត្រូវបង្កើត ឬរក្សាប្រតិបត្តិការហិរញ្ញវត្ថុជាមួយអ្នកខ្ចីប្រាក់ដែរឬយ៉ាងណា ។ ទោះជាយ៉ាងណាក៏ដោយ ប្រការនេះមិនអនុវត្តចំពោះករណីណាដែលបុគ្គលយល់ព្រមជាលាយលក្ខណ៍អក្សរពីការផ្តល់ឱ្យ និងការប្រើប្រាស់ព័ត៌មានឥណទានរបស់ខ្លួនសំរាប់គោលបំណងផ្សេង ឬនៅពេលណាដែលបុគ្គលស្ម័គ្រចិត្តផ្តល់ព័ត៌មានឥណទានរបស់ខ្លួន ។

**ប្រការ ១៥.-**

បន្ទាប់ពីការប្រកាន់យកជំហានសមស្របនានា ក្នុងការបង្កើតអត្តសញ្ញាណរបស់ខ្លួន បុគ្គលម្នាក់អាចស្នើសុំចម្លងឯកសារព័ត៌មានផ្ទាល់របស់ខ្លួនពីធនាគារជាសមាជិកដែលបុគ្គលនោះមានគណនី ។ ក្នុងករណីនេះ បុគ្គលនោះនឹងបានទទួលឯកសារមួយច្បាប់ស្តីពីទិន្នន័យព័ត៌មានឥណទាន ដែលភ្នាក់ងាររក្សាទុកតាមពេលវេលាសមស្រប ។

**ប្រការ ១៦.-**

នៅពេលមានការស្នើសុំពីធនាគារជាសមាជិកណាមួយ ភ្នាក់ងារអាចផ្តល់ជំនួយចាំបាច់ឱ្យបុគ្គលនោះក្នុងការពន្យល់ពីព័ត៌មានឥណទានដែលបានផ្តល់ឱ្យសាមីជន ។

**ប្រការ ១៧.-**

១- ក្នុងករណីដែលបុគ្គលណាម្នាក់ចាត់ទុកថា ព័ត៌មានឥណទានផ្ទាល់របស់ខ្លួន ដែលភ្នាក់ងារបានរក្សាទុកមានលក្ខណៈខុសពីការពិត សាមីជនអាចលើកសំណើឱ្យកែតម្រូវជាលាយលក្ខណ៍អក្សរទៅធនាគារជាសមាជិក។

២- នៅពេលបានទទួលសំណើសុំកែតម្រូវស្របតាមកថាខ័ណ្ឌទី១ នៃប្រការ១៧ ធនាគារជាសមាជិកត្រូវធ្វើការផ្ទៀងផ្ទាត់ក្នុងរយៈពេល៧ថ្ងៃធ្វើការ គិតចាប់តាំងពីកាលបរិច្ឆេទទទួលសំណើសុំកែប្រែមកកាន់ធនាគារ

ជាសមាជិក ដែលជាធនាគារចុះទិន្នន័យពីដំបូង ។ បើសំណើនោះត្រឹមត្រូវ ធនាគារជាសមាជិកដែលជាអ្នកចុះទិន្នន័យគ្រាដំបូង ត្រូវកត់ត្រាទិន្នន័យនោះក្នុងប្រព័ន្ធចែករំលែកព័ត៌មានឥណទានក្នុងរវាង ៧ថ្ងៃធ្វើការគិតចាប់តាំងពីថ្ងៃទទួលសំណើសុំកែតម្រូវ ហើយជូនដំណឹងដល់អតិថិជននិងភ្នាក់ងារ ។

៣- ក្នុងករណីដែលការស្រាវជ្រាវមិនអាចបញ្ចប់ក្នុងរយៈពេល៧ថ្ងៃធ្វើការ គិតចាប់តាំងពីថ្ងៃទទួលសំណូមពរសូមឱ្យកែតម្រូវ ធនាគារជាសមាជិកត្រូវជូនដំណឹងពីលទ្ធផលបណ្តោះអាសន្នដល់បុគ្គលនិងភ្នាក់ងារ ។ ភ្នាក់ងារត្រូវពិនិត្យករណីនេះ ហើយធ្វើសេចក្តីសន្និដ្ឋានសំរេចក្នុងរយៈពេល៧ថ្ងៃធ្វើការ គិតចាប់តាំងពីថ្ងៃបញ្ចប់ការស្រាវជ្រាវ ។

៤- ភ្នាក់ងារ និងធនាគារជាសមាជិកត្រូវរក្សាទុកបញ្ជីឯកសារផ្សេងៗ ដែលរួមមាននីតិវិធី និងលទ្ធផលនៃការស្រាវជ្រាវឥណទាន ។

**ប្រការ ១៨.-**

មន្ត្រី ឬបុគ្គលិកណាមួយរបស់ភ្នាក់ងារ និងធនាគារជាសមាជិកដែលបានទទួលទំនុកចិត្តក្នុងការប្រមូល ផ្សព្វផ្សាយ គ្រប់គ្រង និងប្រើប្រាស់ព័ត៌មានឥណទាន ទោះក្នុងករណីណាក៏ដោយ ក្រៅពីករណីដែលបានរៀបរាប់នៅក្នុងប្រកាសនេះ មិនត្រូវផ្តល់ ឬប្រើប្រាស់ព័ត៌មានឥណទានដែលពួកគេបានដឹងដោយសារការបំពេញការងាររបស់ខ្លួនឡើយ ។

## ជំពូកទី ៥

## បទប្បញ្ញត្តិបន្ថែម

**ប្រការ ១៩.-**

១- ក្នុងករណីភ្នាក់ងារ ឬធនាគារជាសមាជិកធ្វើឱ្យមានការបាត់បង់ទៅលើឯកត្តជន ដោយសារការរំលោភលើប្រការ ១៧ នៃប្រកាសនេះ ភ្នាក់ងារ ឬធនាគារជាសមាជិកត្រូវទទួលខុសត្រូវសងរាល់តម្លៃ បន្ទុក ការខូចខាត បាត់បង់ និងការចំណាយទាំងអស់ដែលបានកើតឡើង ។ ក៏ប៉ុន្តែ ការទទួលខុសត្រូវនេះមិនត្រូវអនុវត្តចំពោះភ្នាក់ងារឬធនាគារជាសមាជិកដែលមិនត្រូវបានរកឃើញថា បានរំលោភដោយចេតនាលើប្រកាសនេះ ដោយមិនស្មោះត្រង់ មានបំណងមិនល្អ និងដោយខ្វះការប្រុងប្រយ័ត្នធ្ងន់ធ្ងរនោះទេ ។

២- ភ្នាក់ងារត្រូវរៀបចំកម្មវិធីទណ្ឌកម្ម និងសោហ៊ុយចំពោះការរំលោភលើប្រកាសនេះ និងក្រមប្រតិបត្តិ ដោយមានការអនុម័តពីធនាគារជាតិនៃកម្ពុជា និងពង្រឹងការអនុវត្តកម្មវិធីទណ្ឌកម្ម និងសោហ៊ុយ ពិន័យដែលបានអនុម័តនេះ ។

**ប្រការ ២០.-**

ប្រធានគណៈកម្មាធិការគ្រប់គ្រងប្រព័ន្ធចែករំលែកព័ត៌មានឥណទាន ត្រូវរៀបចំដោយមានជំនួយរបស់ប្រធានក្រុមប្រតិបត្តិការនូវផែនការថវិកាប្រចាំឆ្នាំ ដើម្បីដាក់ជូនក្រុមប្រឹក្សាភិបាលនៃប្រព័ន្ធចែករំលែកព័ត៌មានឥណទានអនុម័ត ។

**ប្រការ ២១.-**

ធនាគារដែលត្រូវបានបង្កើតស្របតាមច្បាប់ធនាគារ និងបទបញ្ញាពាក់ព័ន្ធផ្សេងទៀត និងអ្នកចូលរួមក្នុងប្រព័ន្ធចែករំលែកព័ត៌មានឥណទាន ត្រូវរក្សាទុករបាយការណ៍ព័ត៌មានឥណទាន ដែលមាននៅក្នុងប្រព័ន្ធចែករំលែកព័ត៌មានឥណទាន និងលិខិតយល់ព្រមរបស់អ្នកខ្ចីដែលមានសម្រាប់គ្រប់ឥណទានទាំងអស់ ព្រមទាំងគណនីឥណទានវិបារូបន៍ របស់អ្នកខ្ចីក្រោយកាលបរិច្ឆេទចុះហត្ថលេខាលើប្រកាសនេះ ។ ក្នុងករណី ធនាគារមិនមែនជាសមាជិករបស់ប្រព័ន្ធ ចែករំលែកព័ត៌មានឥណទាន ធនាគារណាក៏អាចរក្សាទុករបាយការណ៍ព័ត៌មានឥណទានផ្ទៃក្នុងរបស់ខ្លួនបាន ។ ក្នុងករណីនេះ ធនាគារត្រូវបង្ហាញនូវចំណាងទាក់ទងនៃដំណើរការសាកសួរព័ត៌មានឥណទានផ្ទៃក្នុងរបស់ខ្លួន និងទទួលការអនុញ្ញាតពីធនាគារជាតិនៃកម្ពុជា ដើម្បីប្រើប្រាស់គំរូរបាយការណ៍ព័ត៌មានឥណទានផ្ទៃក្នុងរបស់ខ្លួន ។

**ប្រការ ២២.-**

អគ្គនាយកដ្ឋាន អគ្គលេខាធិការដ្ឋាន អគ្គបេឡា អគ្គាធិការដ្ឋាន គ្រប់នាយកដ្ឋាន អង្គភាព គ្រប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុនៅក្រោមឱវាទ និងក្រោមអាណាព្យាបាលធនាគារជាតិនៃកម្ពុជាត្រូវអនុវត្តម៉ឺងម៉ាត់នូវប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ។

**ប្រការ ២៣.-**

ប្រកាសនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។ ៚

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែឧសភា ឆ្នាំ ២០០៦

**ទេសាភិបាល**

**ជា_ចាន់តូ**

**កន្លែងទទួល**

- ដូចប្រការ២២ "ដើម្បីអនុវត្ត"
- កាលប្បវត្តិ
- ឯកសារ

**ចម្លងជូន**

- សមាជិកក្រុមប្រឹក្សាភិបាល
- ទីស្តីការគណៈរដ្ឋមន្ត្រី "ដើម្បីជ្រាបជាពត៌មាន"
- នាយកដ្ឋានរដ្ឋបាលនៃទីស្តីការគណៈរដ្ឋមន្ត្រី "ដើម្បីចុះក្នុងរាជកិច្ច"

**ឧបសម្ព័ន្ធទី ១ នៃប្រកាសស្តីពីការប្រើប្រាស់ និងការការពារព័ត៌មានឥណទាន**

## ពាក្យសុំចូលរួមក្នុងប្រព័ន្ធចែករំលែកព័ត៌មានឥណទាន

**សូមគោរពជូន**

**ឯកឧត្តម ទេសាភិបាលធនាគារជាតិនៃកម្ពុជា**

**កម្មវត្ថុ** : សំណើសុំចូលរួមអនុវត្តការចែករំលែកព័ត៌មានក្នុងប្រព័ន្ធព័ត៌មានឥណទាន ។

ចំពោះសំណើដូចមានក្នុងកម្មវត្ថុខាងលើ ខ្ញុំមានកិត្តិយសសូមជំរាបជូនឯកឧត្តមទេសាភិបាល មេត្តាជ្រាបថា បន្ទាប់ពីបានស្វែងយល់យ៉ាងច្បាស់ពីខ្លឹមសារនៃប្រកាសស្តីពីការប្រើប្រាស់ និងការការពារព័ត៌មានឥណទាន ការចែករំលែកព័ត៌មានឥណទានក្នុងចំណោមធនាគារជាសមាជិក មានអត្ថប្រយោជន៍សំខាន់ក្នុងការលើកស្ទួយឱ្យបានរឹងមាំនូវសកម្មភាពឥណទាន និងគ្រប់គ្រងបាននូវរាល់ហានិភ័យទាំងអស់របស់ធនាគារ ។

អាស្រ័យហេតុនេះ សូមឯកឧត្តមទេសាភិបាលមេត្តាពិនិត្យ ផ្តល់លទ្ធភាពឱ្យធនាគារ ( *ឈ្មោះធនាគារ*) បានចូលជាសមាជិកក្នុងប្រព័ន្ធចែករំលែកព័ត៌មានឥណទានដោយអនុគ្រោះ ។

សូមឯកឧត្តមទេសាភិបាល មេត្តាទទួលនូវការគោរពដោយស្មោះស្ម័គ្រពីខ្ញុំ ។

**ហត្ថលេខា (នីតិបុគ្គល)**

**ឧបសម្ព័ន្ធទី ២ នៃប្រកាសស្តីពីការប្រើប្រាស់ និងការការពារព័ត៌មានឥណទាន**

## គំរូការយល់ព្រមរបស់អ្នកខ្ចីប្រាក់

ខ្ញុំឈ្មោះ ABC (តំណាងឱ្យក្រុមហ៊ុន DEF : ក្នុងករណីអ្នកខ្ចីក្រុមហ៊ុន)

(អាសយដ្ឋាន)

ជំរាបជូនធនាគារ X Y Z

(អាសយដ្ឋាន)

ព័ត៌មានឥណទាន (អវិជ្ជមាន) ដែលលោកអ្នកបានទទួលពីប្រតិបត្តិការអាជីវកម្មរបស់ខ្ញុំ (ក្រុមហ៊ុន DEF ) អាចផ្តល់ឱ្យតតិយជន បានតែនៅពេលមានការអនុញ្ញាតពីរូបខ្ញុំតែប៉ុណ្ណោះ ។ ខ្ញុំសូមអះអាងអំពីការឯកភាពរបស់ខ្ញុំ (ក្រុមហ៊ុន DEF ) ក្នុងការផ្តល់ព័ត៌មានឥណទាន (អវិជ្ជមាន) របស់ខ្ញុំទៅកាន់ទីភ្នាក់ងារមជ្ឈការព័ត៌មានឥណទាន (ធនាគារជាតិនៃកម្ពុជា) ដើម្បីប្រើប្រាស់ ជាជំនួយក្នុងការវាយតម្លៃឱ្យបានត្រឹមត្រូវអំពីភាពគួរឱ្យជឿទុកចិត្តរបស់ខ្ញុំ (ក្រុមហ៊ុន DEF) ។

ប្រភេទនៃព័ត៌មានឥណទានដែលអាចផ្តល់មានដូចខាងក្រោម :

- ព័ត៌មានស្តីពីអត្តសញ្ញាណរួមមានឈ្មោះ លេខអត្តសញ្ញាណប័ណ្ណ លេខចុះបញ្ជីពាណិជ្ជកម្ម អាសយដ្ឋាន វិជ្ជាជីវៈអាជីវកម្ម ។ល។
- ព័ត៌មានឥណទាន (អវិជ្ជមាន) រួមមានកិរិតឥណទាន បរិមាណប្រាក់ជំពាក់ បរិមាណបំណុលកកស្ទះ បរិមាណជាក់ស្តែង ចំនួនប្រាក់នៃមូលប្បទានប័ត្រ និងរូបិយាណត្តិ ដែលមិនបានទូទាត់ កាលបរិច្ឆេទកត់ត្រាចូលប្រព័ន្ធ កាលបរិច្ឆេទលុបចេញពីប្រព័ន្ធ ។ល។

ការយល់ព្រមនេះនឹងមានសុពលភាពនៅថ្ងៃចុះហត្ថលេខា

(ឈ្មោះអ្នកខ្ចីប្រាក់) A B C

__________ (ហត្ថលេខា)

__________ (កាលបរិច្ឆេទកត់ត្រាចូល)

**ឧបសម្ព័ន្ធទី ៣ នៃប្រកាសស្តីពីការប្រើប្រាស់ និងការការពារព័ត៌មានឥណទាន**

តាមរយៈអ៊ីនធឺណែត ឬលិខិតផ្លូវការ

## ពាក្យសុំកែតម្រូវ

កាលបរិច្ឆេទ

ខ្ញុំឈ្មោះ ABC ( តំណាងឱ្យក្រុមហ៊ុន DEF )

( អាសយដ្ឋាន)

ជំរាបមកលោកនាយកធនាគារ XYZ

( អាសយដ្ឋាន)

ខ្ញុំបានពិនិត្យឃើញថា ព័ត៌មានឥណទានរបស់ខ្ញុំ (ឬរបស់ក្រុមហ៊ុន DEF) ដែលបានចុះផ្សាយក្នុងប្រព័ន្ធចែករំលែកព័ត៌មានឥណទាន មិនបានត្រឹមត្រូវតាមការពិត តាមចំណុចមួយចំនួនដូចខាងក្រោម ÷

☐ ឈ្មោះ

☐ អាសយដ្ឋាន

☐ ចំនួនប្រាក់ជំពាក់

☐ ចំនួនប្រាក់កកស្ទះ

☐ មូលហេតុរាយការណ៍

☐ ផ្សេងទៀត ( សូមបញ្ជាក់លំអិត)

អាស្រ័យហេតុនេះ សូមលោកនាយកធនាគារ XYZ ជួយធ្វើការកែតម្រូវតាមការគួរ ។

( ឈ្មោះអ្នកខ្ចីប្រាក់ ) A B C

____________ ( ហត្ថលេខា)

( សូមគូស ☑ ណាមួយ និងប្រាប់ពីព័ត៌មានត្រឹមត្រូវ)

**ឧបសម្ព័ន្ធទី ៤ នៃប្រកាសស្តីពីការប្រើប្រាស់ និងការការពារព័ត៌មានឥណទាន**

**គំរូលិខិតជូនដំណឹងចំពោះអ្នកខ្ចីប្រាក់**

កាលបរិច្ឆេទ :

ធនាគារ X Y Z

( អាសយដ្ឋាន)

ជំរាបជូនលោក លោកស្រី _______________

សូមជំរាបជូនថា លោក លោកស្រី (ឬក្រុមហ៊ុនរបស់លោក លោកស្រី) នឹងត្រូវរាយការណ៍ថាជាអ្នកជំពាក់ប្រាក់ (ឬមិនទាន់សងប្រាក់) ទៅក្នុងប្រព័ន្ធចែករំលែកព័ត៌មានឥណទាន ដែលជាប្រព័ន្ធមជ្ឈការប្រមូលព័ត៌មានឥណទាន ប្រសិនបើលោកអ្នកមិនសងប្រាក់គ្រប់ចំនួនតាមកាលបរិច្ឆេទរាយការណ៍ដែលបានគ្រោងទុក ដូចមានបញ្ជាក់ខាងក្រោម :

**១- ព័ត៌មានឥណទានដែលត្រូវរាយការណ៍ទៅកាន់ប្រព័ន្ធចែករំលែកព័ត៌មានឥណទាន**

| កាលបរិច្ឆេទនៃការទូទាត់សងលើកទី ១ (ឬកាលបរិច្ឆេទនៃការបញ្ជូនមូលប្បទានប័ត្រត្រលប់មកវិញ) | កាលបរិច្ឆេទរាយការណ៍ដែលបានគ្រោងទុកមកកាន់ប្រព័ន្ធចែករំលែកព័ត៌មានឥណទាន | មូលហេតុចំពោះការរាយការណ៍ | បរិមាណប្រាក់ជំពាក់ដែលត្រូវរាយការណ៍ | បរិមាណប្រាក់បំណុលកកស្ទះ (ឬបរិមាណជាក់ស្តែងនៅក្នុងមូលប្បទានប័ត្រគ្មានប្រាក់) |
|---|---|---|---|---|
| | | | | |

**២- ព័ត៌មានសម្រាប់ទាក់ទង**

កាលបរិច្ឆេទ : ម៉ោង ថ្ងៃ ខែ ឆ្នាំ (លេខទូរស័ព្ទ :_____________) ដែលបានជូនដំណឹង/មិនអាចទាក់ទងអ្នកខ្ចី

មូលហេតុស្តីពី "មិនអាចទាក់ទងអ្នកខ្ចី" : (គ្មានការឆ្លើយតប/លេខទូរស័ព្ទមិនត្រឹមត្រូវ/មូលហេតុដទៃទៀត) : បញ្ជាក់ __________

______________________________________________

ប្រសិនបើខ្លឹមសារនៃការជូនដំណឹងខាងលើនេះមិនត្រឹមត្រូវ ឬប្រសិនបើលោកអ្នកមានសំណួរទាក់ទងនឹងការជូនដំណឹងនេះ សូមទាក់ទងមន្ត្រីព័ត៌មានឥណទានតាមអាសយដ្ឋានដូចខាងក្រោម ។

ឈ្មោះធនាគារ: ______________________ ឈ្មោះសាខា : ______________________________

លេខទូរស័ព្ទ : ______________________

ឈ្មោះមន្ត្រី : ______________________

**កំណត់សំគាល់ចំពោះអ្នកខ្ចីប្រាក់ :**

១- គួរកត់សំគាល់ថា យោងតាមវិធាន និងបទបញ្ជាអនុវត្តចំពោះប្រព័ន្ធចែករំលែកព័ត៌មានឥណទាន ព័ត៌មានឥណទានដូចជាបំណុលកកស្ទះ និងប្រាក់មិនទាន់សងដែលត្រូវបានរាយការណ៍ឱ្យប្រព័ន្ធចែករំលែកព័ត៌មានឥណទាននឹងត្រូវរក្សាទុក និងផ្សព្វផ្សាយក្នុងចំណោមធនាគារជាសមាជិកនៃប្រព័ន្ធចែករំលែកព័ត៌មានឥណទានសំរាប់រយៈពេលលើសពី១ឆ្នាំ ទោះបីជាអ្នកខ្ចីប្រាក់ត្រូវបានលុបចេញដោយសារការទូទាត់សងប្រាក់ក្តី ។

២- តាមបញ្ញត្តិច្បាប់ និងបទបញ្ជាដែលអាចអនុវត្តបាន អ្នកខ្ចីប្រាក់មានសិទ្ធិក្នុងការទទួលព័ត៌មានឥណទានផ្ទាល់របស់ខ្លួន និងមានសិទ្ធិក្នុងការកែតម្រូវព័ត៌មានមិនត្រឹមត្រូវ ។

KINGDOM OF CAMBODIA
NATION RELIGION KING

ATIONAL BANK OF CAMBODIA

nber B 7-06 073 PK.

# Prakas

## On

## THE UTILIZATION AND PROTECTION OF CREDIT INFORMATION

### The Governor of the National Bank of Cambodia

- With reference to the Constitution of the Kingdom of Cambodia;
- With reference to the Royal Kram NS/RKM/0196/27, dated January 26, 1996 promulgating the Law on the Organization and Conduct of the National Bank of Cambodia;
- With reference to the Royal Kram NS/RKM/1199/1, dated November 18, 1999 promulgating the Law on Banking and Financial Institutions;
- With reference to the Royal Decree NS/0904/244, dated 7 September 2004 on the appointment of His Excellency **Chea Chanto** as Governor of the National Bank of Cambodia, in equivalent to Senior Minister;
- Pursuant to the agreement reached at the meeting of the senior officials of the National Bank of Cambodia, dated May 04, 2006

### DECIDES

### Chapter 1

### General Provision

**Article 1.-**

The purpose of this Prakas is to promote the sound credit activities and risk management of all entities participating in the financial system by authorizing the establishment of the Centralized Credit Information Collection Agency that collects and shares the Negative Credit Information relating to bank Borrowers amongst Member Banks and by protecting the secrecy of Borrower Information from the misuse and abuse of the credit information.

**Article 2.-**

Definitions of technical words ant terms used in this Prakas:

- "**Banking Law**" means the Law on Banking and Financial Institutions.

- "**Central Bank Law**" means the Law on the Organization and Conduct of the National Bank of Cambodia.
- "**Credit Information**" refers to any information on the borrower which is obtained in connection with the provision of credit facility, or any information which is required for identifying and assessing borrower's creditworthiness.
- "**Centralized Credit Information Collection Agency**" or "**Agency**" refers to the institution which is engaged in collecting, disseminating, and managing credit information.
- "**Credit Information System**" refers to software, hardware and governance that are required for the daily function of the Agency.
- "**Member Banks**" refer to banks which are established under the law on banking and financial institution of the Kingdom of Cambodia and other regulations, provide credit facility to borrowers and sign Code of Conduct to submit credit information to the Agency.
- "**Other Participants**" refers to a person, entity and financial institutions other than banks who have intention to be participants of the CIS and who are approved for the participants by the National Bank of Cambodia.
- "**Credit Facility**" refers to loan or any other kind of credit provided to the borrower by a financial institution.
- "**Borrower**" refers to an individual or a business entity for which the credit facility is provided.
- "**Identification Information**" refers to information which is required to assess the correct identification of an individual or a business entity.
- "**Negative Credit Information**" refers to information on overdue loans (more than 90 days past due), including principal and interest, and defaults on overdraft account as defined in the Code of Conduct.
- "**Arrears**" refers to more than 90-days overdue loans as defined in the Subject 18, Appendix 4 (Definition of Terms and Parameters Used in the CIS) of the Code of Conduct.
- "**Default**" refers to returned checks or dishonored bills due to insufficient or no funds or other reasons as specified in the Subject 18, Appendix 4 of the Code of Conduct.

**Article 3.-**

1. Banks which are established under the Banking Law and other regulations and have intention to participate in the CIS shall sign the Code of Conduct with the National Bank of Cambodia.
2. The Code of Conduct that describes the collection, dissemination, management, and utilization of credit information shall be prepared and enforced by the National Bank of Cambodia.
3. The terms and conditions of the Code of Conduct may be modified from time to time as determined by the National Bank of Cambodia or in agreement with the CIS Management Committee.

4. A person, entity and financial institutions other than bank who have intention to be participants of the CIS may submit applications for participation to the National Bank of Cambodia.

**Article 4.-**

The National Bank of Cambodia shall designate the Chairman of the Board of the Directors of the Agency hereafter "CIS Board of Directors" who will be in charge of its operations. The Chairman may delegate the supervision and control of the daily function to a Management Committee Chair.

## Chapter 2

## Establishment of the Credit Information System

**Article 5.-**

1. The NBC shall be the Agency engaged in operating and managing the CIS and developing various policies regarding its ongoing operations.
2. The Agency shall develop and maintain the web-based credit information sharing system through which member banks and the authorized other financial institutions shall report and share centralized credit information.
3. The Agency shall be comprised of CIS Board of Directors, Management Committee and Operations Team. The Chairman of the CIS Board of Directors shall appoint 6 to 8 directors from within the Agency and from Member Banks, if necessary. Members of the Management Committee other than necessary number of participants from the Agency may include representatives of Member Banks recommended by the CIS Board of Directors, a representative of the Association of Banks in Cambodia and expert person(s) recommended by the CIS Board of Directors. The Operations Team shall be comprised of a leader and staffs of the IT Office of the Agency.
4. The Agency is authorized to impose penalty or suspend the CIS membership of the member banks and other participants who are in breach of the Code of Conduct.

**Article 6.-**

1. Member Banks and other participants of the CIS are hereby authorized to submit credit information in an electronic data format on a regular basis as specified in the guidelines to the Agency for the purpose of sharing credit information.
2. Any officer or employee and Member Bank who honestly manages and reports credit information into the CIS cannot be held liable for a breach of Chapter 15 on Professional Secrecy of the Law of Banking and Financial Institutions, unless he or she makes a breach in Article 18 of this Prakas .
3. Member Banks are authorized to have access to the credit information system managed by the Agency and utilize the credit information solely for the purpose of assessing the credit worthiness of a borrower.

## Chapter 3

## Management of Credit Information

**Article 7.-**

1. The Agency shall establish the Management Committee in order to make the decision on the items listed below through consultation. Items (a) through (c) require the approval by the CIS Board of Directors prior to action. Items (d) and (e) can be determined and implemented by the Chair of the Management Committee, but they must be reported to the CIS Board of Directors ex post.
    a. Matters pertaining to concrete Kinds of credit information to be collected by the Agency and retention period under the provision of the applicable Law
    b. Matters pertaining to Bearing/Sharing and Settlement of the operational cost that is incurred in the process of centralized collection, management, and utilization of credit information by the Agency and investment on a new project
    c. Matters pertaining to the investigation of the actual conditions of compliance with duties of financial institutions to provide credit information and imposition and usage of penalties
    d. Matters pertaining to a preventive measure in case of misuse and leakage of credit information for purposes other than permitted by the Law
    e. Specifics necessary for centralized collection, management, and utilization of credit information and supervision of the CIS Operations Team.
2. A Chair of the Management Committee shall be appointed by a Chairman of the CIS Board of Directors.
3. A Chair of the Management Committee shall organize and supervise the CIS Operations Team for daily functions of the CIS. A Leader of Operations Team shall be nominated among the staffs of the IT Office of the Agency and be appointed by the Chairman of the CIS Board of Directors.

**Article 8.-**

1. The Agency should manage credit information in such a manner that credit information is accurate and up-to-date.
2. Out-dated credit information beyond the retention period that can give rise to disadvantage to Customers must be removed from the credit information system.

**Article 9.-**

The Agency shall implement necessary technological and physical security measures in order to protect credit information from any third party's unauthorized access, loss, alteration, damage or destruction of credit information and other external threats arriving over the network.

**Article 10.-**

The Agency shall prepare the Management Guidelines that clarify the internal procedures for the collection, management, and utilization of the credit information.

## Chapter 4

## Protection of Borrowers' Credit Information

**Article 11.-**

The Agency shall publicly disclose the matters regarding the type of credit information to be collected, disseminated, managed and utilized, the purpose of credit information management, the recipient of credit information and the rights of borrowers with regard to this subject.

**Article 12.-**

In case each Member Bank intends to provide individual credit information on the items listed below to the Agency, it shall obtain consent in writing from the individual using the form in Annex 2 of this Prakas.

(a) Outstanding loans

(b) Identity information such as Individual's name, address, and identification number.

(c) Specifics listed in the Code of Conduct

**Article 13.-**

Member Bank shall notify Borrower before reporting borrower's negative credit information to the Agency and keep a record of Notification to Borrower Form from Annex 4 of this Prakas.

**Article 14.-**

Individual credit information shall be provided and utilized exclusively for the purpose of assessing borrower's creditworthiness and judging whether to establish or maintain financial transaction with the borrower. However, this shall not apply to cases where the individual consent in writing to the provision and utilization of his or her credit information for other purposes, or where the individual voluntarily provide his or her credit information.

**Article 15.-**

An individual may, after taking all reasonable steps to establish his or her identity, request a perusal copy of one's own credit information to a Member Bank where he or she maintains his or her account. In such case, the individual shall be provided with a copy of credit information record retained by the Agency within reasonable time.

**Article 16.-**

Upon request from a Member bank, the Agency may provide necessary assistance

to the individual in explaining the credit information released to him or her.

**Article 17.-**

1. In case the individual considers one's own credit information retained by the Agency to be different from the fact, he or she can make a correction request in writing to a Member Bank or to the Agency.
2. Upon receipt of a correction request made pursuant to Paragraph 1 of Article 17, a Member Bank and the Agency shall send the Request for Verification, from using the CIS web screen, within seven (7) business days from the date of receipt of correction request to Member Bank who initially registered data. If the request is valid, the Member Bank who initially registered data shall have it recorded to the credit information system within seven (7) business days from the date of receipt of correction request and notify the customer.
3. In case the investigation cannot be completed within seven (7) business days from the date of receipt of correction request, the Member Bank shall notify the interim results to the individual and Agency. The Agency shall examine the case and deliver final conclusion within seven (7) business days from the date the investigation is completed.
4. The Agency and Member Banks shall retain records that include procedures and results of the credit investigation.

**Article 18.-**

Any officer or employee of the Agency and a Member bank who is entrusted with the collection, dissemination, management and utilization of credit information shall not for any purpose other than prescribed in this Prakas reveal or make use of individual's credit information which they have become aware in connection with the performance of his/her duties.

## Chapter 5

## Supplementary Provisions

**Article 19.-**

1. In case the Agency or a Member bank inflict a loss on the individual due to the violation of Article 17, they shall be held responsible for indemnification against all costs, charges, losses, damages and expenses incurred. However, this shall not apply when the Agency or a Member bank are not found liable for any willful violation of this Prakas, bad faith, malice and gross negligence.
2. The Agency shall prepare the penalty and fee schedule for violation of this Prakas and the Code of Conduct, obtain the approval from the National Bank of Cambodia, and enforce the approved penalty and fee schedule.

**Article 20.-**

A Chair of the CIS Management Committee shall prepare, with an aid from the Operations Team Leader, the annual budgetary plan for an approval by the CIS Board of Directors.

**Article 21.-**

Banks established under the Banking Law and other regulations and other participants to the CIS shall keep the Credit Information Report that is available from the CIS and the Borrower Consent Form for all loans made out and overdraft account established for borrowers after the signing date of this Prakas. In case that a bank is not a member bank to the CIS, a bank may keep its own internal credit information report instead. In this case, bank should demonstrate the relevance of its internal credit information inquiry process and acquire the permission from the National Bank of Cambodia to use its internal credit information report form instead.

**Article 22.-**

The Direction General, the Secretariat General, the Inspection General, the Cashier General, all Departments of the National Bank of Cambodia, and all Banks and Financial Institutions, and the Representative Offices of foreign banks under the National Bank of Cambodia's supervisory authority shall strictly implement this Prakas.

**Article 23.-**

Other previous provisions contrary to this Prakas are hereby repeated.

**Article 24.-**

This Prakas shall have affect from the signing date.

Phnom Penh, May 10, 2006

**The Governor**

**Signed and sealed: Chea Chanto**

cc:
- The parties concerned as stated in Article 22
- Administrative
- File
- The member of the Board of Directors
- CM "for info."
- Department of CM "for publication in the National Gazette"

**Annex 1 of Prakas on the Utilization and Protection of Credit Information**

## Application for Participant of the CIS

Governor
National Bank of Cambodia

**Subject**: Request for participation in CIS.

As mentioned in the above subject, I have the honor to inform H.E. the Governor that after fully understand the meaning of the Prakas on the Utilization and Protection of Credit Information, the credit information sharing among bank is very useful in enhancing the sound credit activities and in managing all banking risks involved.

Therefore, I would like to request the pleasure to H.E. the Governor to consider the possibility to authorize (the bank's name) to join as a participant of the credit sharing information system, which has been established by the Asian Development Bank.

Please the Governor accepts our high consideration.

Signature (Legal Entity)

**Annex 2 of Prakas on the Utilization and Protection of Credit Information**

## Borrower Consent Form

XYZ Bank
(address)

Dear XYZ Bank,

The (negative) credit information that you acquired from my business transactions can be provided to a third party only upon my consent. Hereby I confirm my agreement on providing my (negative) credit information to the Centralized Credit Information Agency (NBC) for the purpose of assisting accurate assessment of my creditworthiness.

The types of credit information which will be provided are as follows:

- Identification information, including Name, ID number/Business Registration number, address, business profession, and etc.

- (Negative) credit information, including credit line, outstanding amount, amount in arrears, nominal amount on defaulting checks and bills, date of recognition, release, and etc.

This agreement will become effective on the date of signature.

ABC (Borrower Name)

__________ (Signature)
__________ (Date)

**Annex 3 of Prakas on the Utilization and Protection of Credit Information**

- Through Web or formal letter

## Request for Correction

Date:

I am ABC (representative of DEF Company)
Address

To: XYZ Bank
Address

I noticed that my credit information (or of DEF company), which had been reported in the Credit Sharing Information System is not accurate as stated followed:

☐ Name
☐ Address
☐ Arrears
☐ Reporting reason
☐ Other (please state the details)

Therefore, please rectify this information accordingly.

Signature

(Please tick in the box ☑ and state the correct information)

**Annex 4 of Prakas on the Utilization and Protection of Credit Information**

**Notification to Borrower Form**

XYZ Bank
(address)

Date:

Dear Mr./Mrs./Ms. ________________ ,

This is to notify that you (or your company) are going to be reported as delinquent (or defaulting) borrower to the Credit Information System, which is the centralized credit information collection agency, unless you make full repayment within expected report date indicated below:

1. Credit information to be reported to the CIS

| Date of first missed payment (or Date check is returned) | Expected reporting date to the CIS | Reason for reporting | Outstanding amount to be reported | Amount in arrears (or nominal amount in defaulting check) |
|---|---|---|---|---|
| | | | | |

2. Contact Information

| |
|---|
| Date: hour dd/mm/yy (phone number: ______________) Informed / Cannot reach borrower<br>Reason for "cannot reach borrower": ( no response / wrong telephone number / other reason: specify _________________ |

If the content of the above notification is incorrect or you have any inquiry regarding this notification, please contact the following credit information officer.

Bank Name: ___________ Branch Name: _______________
Phone Number: ____________________________________
Name of Officer: ____________________________________

Note to Borrowers:

1. It shall be noted that, according to the rules and regulations applicable to the CIS, the credit information such as arrears and default reported to the CIS would be retained and shared among the CIS Member Banks more than one year even if borrower is released because of the repayment.
2. Under the provisions of applicable laws and regulations, borrowers are entitled to have the access to own credit information and rights to rectification of incorrect information.

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ១១៧៥ ពណ.នតក

ភ្នំពេញថ្ងៃទី ០៣ ខែ ឧសភា ឆ្នាំ ២០០៦

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

**សូមបញ្ជាក់ថា :**

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយ ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅ តាមលក្ខខ័ណ្ឌដូចខាងក្រោម :

| | | |
|---|---|---|
| ១- | នាមករណ៍របស់ក្រុមហ៊ុន | : **ណាយស៍ ស្តារ ប្រូដាក់ស៊ិន ហៅស៍** |
| | | **NICE STARS PRODUCTION HOUSE Co.,Ltd.** |
| | អត្តលេខចុះបញ្ជីពាណិជ្ជកម្ម | : **Co. 8643/06P** ចុះថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ២០០៦ |
| | មានទ្រង់ទ្រាយជា | : សហគ្រាសឯកបុគ្គលទទួលខុសត្រូវមានកំរិត |
| ២- | អភិបាលក្រុមហ៊ុន | : លោក **ហៃ្វ សំអាង** |
| ៣- | ដើមទុនក្រុមហ៊ុន | : ចំនួន ២០.០០០.០០០ រៀល |
| ៤- | ទីស្នាក់ការក្រុមហ៊ុន | : ផ្ទះលេខ ៣៦ ផ្លូវលេខ ៨៧ ភូមិត្នោតជុំ សង្កាត់បឹងទំពុន ខណ្ឌមានជ័យ រាជធានីភ្នំពេញ |
| ៥- | កម្មវត្ថុអាជីវកម្ម | : -ផលិតខ្សែភាពយន្តវីដេអូ CD |

-ពាណិជ្ជកម្ម : ទិញ លក់ ផ្លាស់ប្តូរទំនិញ នីហរ័ណ អាហរ័ណទំនិញគ្រប់ប្រភេទ នាំចូលឱសថ សំភារៈបរិក្ខារពេទ្យគ្រប់ប្រភេទ

-ការជួលដាក់ឃ្លាំងនូវផលិតផល ទំនិញគ្រប់ប្រភេទ -ការជួសជុលសំភារៈ ទំនិញគ្រប់ប្រភេទ

-ទិញ លក់ ជួល បញ្ចាំមូលនិធិពាណិជ្ជកម្ម-ទិញ លក់ ជួល ដីធ្លី ផ្ទះសំបែង

-ប្តូរប្រាក់ ផលិត ទិញ លក់ គ្រឿងអលង្ការ

-មន្ទីរពេទ្យពិគ្រោះព្យាបាលជំងឺ

-បើកសាលារៀន

-សេវាយកកំរៃជើងសារ -ភ្នាក់ងារពាណិជ្ជកម្ម -តំណាងពាណិជ្ជកម្ម

-សេវាពិគ្រោះយោបល់លើផ្នែកហិរញ្ញវត្ថុ ពាណិជ្ជកម្ម

-សេវារកការងារជូនអតិថិជនធ្វើក្នុងនិងក្រៅប្រទេស

-សេវាផ្សាយពាណិជ្ជកម្ម

-បោះពុម្ពផ្សាយ

-ដឹកជញ្ជូន : ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស -សេវាបញ្ជូន និងចែកចាយទំនិញ

-សេវាយកកំរៃជើងសារលើការដឹកជញ្ជូន

-សាងសង់ ជួសជុល អាគារ ស្ពាន ថ្នល់

-ទេសចរណ៍ : សណ្ឋាគារ ភោជនីយដ្ឋាន ...

-វិនិយោគលើវិស័យកសិកម្ម : ដាំដំណាំ ចិញ្ចឹមសត្វ

-វិនិយោគលើវិស័យឧស្សាហកម្ម : រោងចក្រ សិប្បកម្ម ។

៦- ថិរវេលា : ៩៩ ឆ្នាំ

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬ ស្ថាប័ន ដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងទីស្នាក់ការរបស់ក្រុមហ៊ុន ពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។

ជ.ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

រដ្ឋលេខាធិការ

គឹម ស៊ីថន

**ចំលងជូន**

- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួង ការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសុខាភិបាល
- ក្រសួងទេសចរណ៍
- ក្រសួងពត៌មាន
- ធនាគារជាតិនៃកម្ពុជា
- ក្រសួងអប់រំយុវជន និងកីឡា
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- ក្រសួងកសិកម្ម រុក្ខា ប្រម៉ាញ់ និងនេសាទ
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- អគ្គនាយកដ្ឋានរាជកិច្ច និង សេវាកុំព្យូទ័រ
- សាលាក្រុងភ្នំពេញ
- មន្ទីរពាណិជ្ជកម្មរាជធានី ភ្នំពេញ "មុខការ"
- ឯកសារ -កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce

លេខ ១១៧៦ ពណ.នតក

ភ្នំពេញថ្ងៃទី ០៣ ខែ ឧសភា ឆ្នាំ ២០០៦

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

**សូមបញ្ជាក់ថា ៖**

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយ ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅ តាមលក្ខខ័ណ្ឌដូចខាងក្រោម ៖

១- នាមករណ៍របស់ក្រុមហ៊ុន : **កំពត ស្ពេសល អ៊ីឃើណមិក ហ្សូន**
**KAMPOT SPECIAL ECONOMIC ZONE Co.,Ltd.**

អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : Co. 8664/06P ចុះថ្ងៃទី ២៨ ខែមេសា ឆ្នាំ ២០០៦

មានទ្រង់ទ្រាយជា : ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកំរិត

២- អភិបាលក្រុមហ៊ុន : លោក **ទិញ ម៉ិរ** ប្រធានក្រុមប្រឹក្សាភិបាល
លោកស្រី **ម៉ូ នេងសៀង** អភិបាល

៣- ដើមទុនក្រុមហ៊ុន : ចំនួន ៤.០០០.០០០.០០០ រៀល

៤- ទីស្នាក់ការក្រុមហ៊ុន : ឃុំកោះតូច ស្រុកកំពត ខេត្តកំពត ។

៥- កម្មវត្ថុអាជីវកម្ម : -ពាណិជ្ជកម្ម ៖ ទិញ លក់ ផ្លាស់ប្តូរទំនិញ នីហរ័ណ អាហរ័ណទំនិញ គ្រប់ប្រភេទ
-នាំចូលឱសថ សំភារៈបរិក្ខារពេទ្យគ្រប់ប្រភេទ
-ការជួលដាក់ឃ្លាំងនូវផលិតផល ទំនិញគ្រប់ប្រភេទ-ការជួសជុលសំភារៈទំនិញគ្រប់ប្រភេទ
-ទិញ លក់ ជួល បញ្ចាំមូលនិធិពាណិជ្ជកម្ម -ទិញ លក់ ជួល ដីធ្លី ផ្ទះសំបែង
-ប្តូរប្រាក់ ផលិត ទិញ លក់ គ្រឿងអលង្ការ
-មន្ទីរពេទ្យពិគ្រោះព្យាបាលជំងឺ
-បើកសាលារៀន
-សេវាយកកំរៃជើងសារ -ភ្នាក់ងារពាណិជ្ជកម្ម -តំណាងពាណិជ្ជកម្ម
-សេវាពិគ្រោះយោបល់លើផ្នែកហិរញ្ញវត្ថុ ពាណិជ្ជកម្ម
-សេវារកការងារជូនអតិថិជនធ្វើក្នុងនិងក្រៅប្រទេស
-សេវាផ្សាយពាណិជ្ជកម្ម
-បោះពុម្ពផ្សាយ
-ផលិតខ្សែភាពយន្ត វីដេអូ
-ដឹកជញ្ជូន ៖ ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស សេវាបញ្ជូននិងចែកចាយទំនិញ
-សេវាយកកំរៃជើងសារលើការដឹកជញ្ជូន

-សាងសង់ ជួសជុល អាគារ ស្ពាន ថ្នល់

-ទេសចរណ៍ : សណ្ឋាគារ ភោជនីយដ្ឋាន មជ្ឈមណ្ឌលកំសាន្ត

-វិនិយោគលើវិស័យកសិកម្ម : ដាំដំណាំ ចិញ្ចឹមសត្វ

-វិនិយោគលើវិស័យឧស្សាហកម្ម : រោងចក្រ សិប្បកម្ម

៦- ថិរវេលា : ៩៩ ឆ្នាំ

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬ ស្ថាប័ន ដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងទីស្នាក់ការរបស់ក្រុមហ៊ុន ពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។/

ជ.ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

រដ្ឋលេខាធិការ

គឹម_ស៊ីថន

**ចំលងជូន**

- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសុខាភិបាល
- ក្រសួងទេសចរណ៍
- ក្រសួងពត៌មាន
- ធនាគារជាតិនៃកម្ពុជា
- ក្រសួងអប់រំយុវជន និង កីឡា
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
